ខ្មែរប៉ុស្តិ៍ ស.រ.អា
KhmerPost USA
Printing The Cambodian World News
VOL. 05 ISSUE 82 May 06th - 20th, 2011
សុបិន : (267) 253-3947, សែម : (781) 244-0522
MASSACHUSETTS
217 APPLETON ST.
LOWELL, MA 01852
PENNSYLVANIA
P.O.BOX 24357
PHILADELPHIA, PA 19120
RHODE ISLAND
NEW JERSEY

មាតិការឿង ទំព័រ

១- ដំណោះស្រាយសម្រាប់ទប់ស្កាត់..........០៥
២- អាថ៌កំបាំង និងសិល្បៈនៃជីវិត..........០៦
៣- ទិវាសម្រាប់មាតា និងយោបល់ព្រះសង្ឃ..........០៧
៤- The Cambodia Daily..........០៨
៥- Cambodian Community in Lynn,..........១០
៦- កំណើនសេដ្ឋកិច្ចនៅកម្ពុជា..........១៣
៦- OLNEY STANDS AGAINST..........១៦

# ខ្មែរប៉ុស្តិ៍ចូលឆ្នាំថោះជាមួយសហគមន៍លីន_រីវៀ

**ខ្មែរប៉ុស្តិ៍ ស.រ.អា**

សំលៀកបំពាក់ស្រ្តីខ្មែរប្រមាណ ២០ឈុត បានត្រូវបង្ហាញខ្លួនដ៏ស្រស់បំព្រងនៅមុខអភិបាលក្រុងលីន ផូឌីត កិណ្ណីឌី និងអនុប្រធានគណៈក្រុមប្រឹក្សាក្រុងរីវៀ អែរ៉ា ណូវ៉ូសែលស្គី ចូលរួមដោយបញ្ញាវន្ត និងពាណិជ្ជករខ្មែរ ក្មេងចាស់ប្រមាណ១៥០នាក់នៅរាត្រីចូលឆ្នាំខ្មែរ ឆ្នាំថោះ ព.ស ២៥៥៥ ដែលរៀបចំឡើងដោយខ្មែរប៉ុស្តិ៍ ស.រ.អា សម្រាប់ជាកិត្តិយសដល់ ទីក្រុងលីន និងរីវៀ នៅមជ្ឈមណ្ឌលអតីតយុទ្ធជនថ្ងៃទី២៣ មេសា ២០១១ ។

សុផលីណា ជាអ្នកតុបតែងឱ្យមានកម្មវិធីបង្ហាញម៉ូតជាលើកដំបូងបង្អស់នៅរដ្ឋម៉ាសាឈូសែត នារាត្រីនោះបានប្រើពេលជាងមួយខែសម្រាប់តុបតែងបង្ហាត់បង្ហាញក្រុមនារីបង្ហាញម៉ូត១៥រូបរបស់ខ្លួនដោយគ្មានគិតនឿយហត់ ហើយលទ្ធផលនៃរាត្រីនោះ គឺបានធ្វើឱ្យភ្ញៀវមានចិត្តរំភើប និងចាប់ចិត្តឥតឧបមា ។ ការតុបតែងសាលទទួលភ្ញៀវពណ៌ស និងផ្កាឈូករបស់ សុផាលីណា នាថ្ងៃនោះ ក៏ជរដោយភ្លេងសម័យញាប់រន្ថើន បានលើកលំអរ មិនត្រឹមតែតួរនារីម៉ូតរបស់នាងតែប៉ុណ្ណោះទេ ថែមទាំងលើកសម្រស់ភ្ញៀវឱ្យរីកស្រស់បស់ រីករាយថែមទៀត ។

អគ្រា នារាត្រីនោះជាពិធីករពីរភាសាបានធ្វើការណែនាំពិធីដ៏សំខាន់សម្រាប់សហគមន៍ខ្មែរឱ្យមានមោទនភាពខ្ពស់ដោយប្រយោគខ្លីៗ និងសំខាន់ជូនភ្ញៀវស្តាប់ដោយគ្មានការធុញទ្រាន់ ។ (តទៅទំព័រទី ២០)




សុផលីណា កំពុងបង្ហាញកម្មវិធីបង្ហាញម៉ូតសំលៀកបំពាក់ខ្មែរ

## ព្រះរាជពិធីមង្គលការព្រះអង្គម្ចាស់វិលៀមជាមួយនាងខេត

**ដោយ : គិម វិមល**



•••កម្មវិធីទូរទស្សន៍ដែលមនុស្សលោកតាមដានច្រើនជាងគេនាថ្ងៃសុក្រទី២៩ ខែមេសាកន្លងទៅ គឺព្រះរាជពិធីមង្គលការនៅព្រះរាជវាំង ប៊ើមីងហ្គាម នៃចក្រភពអង់គ្លេស រវាងព្រះអង្គម្ចាស់វិលៀម ជាអនាគតស្តេចចក្រភពលំដាប់ទីពីរជាមួយនឹងនាង ខេត ដែលកើតក្នុងត្រកូលរាស្ត្រសាមញ្ញម្នាក់ ។

កាសែតនៅយូរ៉ុប ចុះផ្សាយថ្ងៃទី១ ខែឧសភានេះថា : "ព្រះអង្គម្ចាស់ទំនងជានឹងយាងចេញទៅសម្រាករាត្រីទឹកឃ្មុំជាមួយនាង ខេត នៅចុងខែឧសភានេះចំនួន១០ថ្ងៃ នៅកោះសេស្សែស ដែលស្ថិតនៅកណ្តាលមហាសាគរឥណ្ឌា (តទៅទំព័រទី ១៥)

## ប៊ីនឡាដេន ឈប់ធ្វើភេរវកម្មបានទៀតហើយ

**ខ្មែរប៉ុស្តិ៍ ស.រ.អា**

•••មេភេរវកម្មដ៏ធំក្នុងលោក ប៊ីនឡាដេន បានត្រូវកងកម្លាំងទ័ពពិសេសអាមេរិកាំងសម្លាប់បានកាលពីថ្ងៃអាទិត្យ ទី១ ខែឧសភា ឆ្នាំ២០១១នេះ កន្លែងលាក់ខ្លួនសម្ងាត់មួយនៅអាបូតាបាត មិនឆ្ងាយប៉ុន្មានពីទីក្រុងអ៊ីស្លាមាបាត នៃប្រទេសប៉ាគីស្ថាន ។ គេនៅចាំបានថា គឺប៊ីនឡាដេន នេះហើយដែលជាមេក្លោងនៃចលនាភេរវកម្មសាសនាអ៊ីស្លាមអាល់កៃដា ដែលបានរៀបគម្រោងពង្វាងយន្តហោះស៊ីវិលឱ្យបើកបុកអាគារទល់មេឃនៅញូវយ៉ក និងអាគារបញ្ជាការទ័ពអាមេរិកាំង ប្រកបដោយជោគជ័យ នាឆ្នាំ២០០១។ (តទៅទំព័រទី ០៤)



GATEWAY FAMILY DENTAL
NOW OPENED AT GATEWAY CENTER II (978) 455-5044
151 WARREN STREET, SUITE 120 LOWELL, MA 01852
(Same building as Social Security/near the courthouse)



DR. SERENA B. CHUOP
Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.

WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ:
- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN
- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ៃនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាបន្ទាន់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

MOST DENTAL INSURANCES ACCEPTED INCLUDING MASSHEALTH FOR KIDS FINANCING AVALIABLE
យើងទទួលនូវគ្រប់ អ៊ិន ស៊ូរ៉ិន Masshealth for Kids
យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ
CALL FOR YOUR FREE CONSULTATION (978) 455-5044

GENERAL DENTISTRY

# ពេទ្យធ្មេញសម្រាប់គ្រួសារ ហួ ឌួង

## 466 Merrimack Street. Lowell, MA 01854
## ( Near City Hall )/ 978-441-1005

**HOA DUONG, D.M.D., P.C.**

**GENERAL DENTISTRY**

គ្រូពេទ្យជំនាញនិងមានបទពិសោធន៍
ច្រើនឆ្នាំក្នុងការពិនិត្យ
ថែរក្សា និងព្យាបាលជម្ងឺធ្មេញទូទៅ



Open: Monday, Tuesday, Wednesday, and Friday
from 10 a.m. – 6 p.m.
Saturday: from 10 a.m. – 4 p.m.
Closed: Thursday & Sunday
We accept all dental insurance & Medicaid



យើងទទួលយកគ្រប់ក្រុមហ៊ុន
ធានារ៉ាប់រងសុខភាព និងការធានារ៉ាប់រង
សុខភាពមនុស្សចាស់

**យើងបើកទ្វារទទួលភ្ញៀវ ៥ថ្ងៃ ក្នុងមួយសប្តាហ៍**
**បិទទ្វារ : ថ្ងៃព្រហស្បតិ៍ និងថ្ងៃ អាទិត្យ**

**ទូរស័ព្ទដើម្បីណាត់ជួប (978) 441-1005**
**ម៉ោងធ្វើការពីម៉ោង 10ព្រឹក ដល់ 6ល្ងាច**
**ថ្ងៃសៅរ៍ ពីម៉ោង 10ព្រឹក ដល់ 4រសៀល**
**យើងមានបុគ្គលិកនិយាយភាសាខ្មែរ**



# ទិវាស្វែងយល់អំពី សុខភាពសម្រាប់ ស្រ្តី អាស៊ី-អាមេរិកាំង ឆ្នាំទីប្រាំពីរ



## ថ្ងៃសៅរ៍ ទី៤ ខែមិថុនា ឆ្នាំ២០១១

ម៉ោង ១០ ព្រឹក ដល់ ២:៣០ រសៀល

នៅសណ្ឋាគារ **Sheraton Philadelphia City Center Hotel**

អាស័យដ្ឋាន៖ **17th & Race Streets, Philadelphia**

*សិក្ខាសាលាស្តីអំពីសុខភាពស្រ្តី មានជាភាសាអង់គ្លេស និងភាសាអាស៊ីផ្សេងៗ ដោយឥតគិតថ្លៃ

*ភូមា • ខ្មែរ • ចិនកុកងឺ • ចិនកន្តាំង • គូចារ៉ាទី • ហ៊ិនឌី • ឥណ្ឌូណេស៊ី • កូរ៉េ • មេឡាយ៉ាឡាំ • ណេប៉ាល់ • វៀតណាម*

*សិក្ខាសាលាសម្រាប់អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេ ដោយឥតគិតថ្លៃ

*នឹងផ្តល់ជូននូវអាហារពេលថ្ងៃ

*មានគ្រឿងកំសាន្តពីសហគមន៍អាស៊ី

*មានព័ត៌មានផ្សេងៗអំពីសហគមន៍អាស៊ី

*ចុះឈ្មោះថតសុដន់ការពាររោគមហារីក (mammograms) ដោយឥតគិតថ្លៃ

American Cancer Society®

THE OFFICIAL SPONSOR OF BIRTHDAYS.®

SUSAN G. KOMEN FOR THE CURE. PHILADELPHIA

cancer.org | 1.800.227.2345
komenphiladelphia.org | 215.238.8900

---

**លិខិតបំពេញដើម្បីចុះឈ្មោះ**

សូមផ្ញើលិខិតចុះឈ្មោះនេះមកវិញឲ្យទាន់ **ថ្ងៃសុក្រ ទី២៧ ខែឧសភា ឆ្នាំ២០១១**

ឈ្មោះ៖ ______________________ លេខទូរស័ព្ទ៖ ______________

អាស័យដ្ឋាន៖ ______________ ទីក្រុង៖ __________ រដ្ឋ៖ _____ លេខតំបន់៖ __________

*សូមរើសយកសិក្ខាសាលាតែមួយគត់៖

☐ សិក្ខាសាលាសម្រាប់សុខភាពស្រ្តីទូទៅ ឬ ☐ សិក្ខាសាលាសម្រាប់អ្នកនៅរស់ពីរោគមហារីក និងអ្នកមើលថែរបស់ពួកគេ

សូមផ្ញើទៅ៖ Wan Ling Hung, American Cancer Society, 1626 Locust Street, Philadelphia, PA 19103
ទូរសារ៖ 215.985.5406 ទូរស័ព្ទ៖ 215.985.5307 (ភាសាអង់គ្លេស)

ទូរស័ព្ទ៖ Cambodian Association of Greater Philadelphia, 215.324.4070 (ខ្មែរ) ឬ PASSi, 215.572.1234 (ភាសាខ្មែរ)

សូមថ្លែងអំណរគុណជាពិសេសដល់៖

GlaxoSmithKline Oncology NOVARTIS ONCOLOGY UnitedHealthcare

(Cambodian)

តមកពីទំព័រទី ០១

# ប៊ីនឡាដេន ឈប់ធ្វើភេរវកម្ម...

ជោគជ័យរបស់អាល់កៃដានេះ ដែលបានសម្លាប់ជនអាមេរិកាំងប្រមាណ៣ពាន់នាក់ ប៉ុន្តែការវាយបករបស់សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តបានកំទេចប្រទេសដែលផ្តល់ជម្រកឱ្យភេរវករពីរឱ្យទៅជាផេះ ប្តូររូបភាពដឹកនាំប្រទេសទាំងស្រុង ហើយនៅតែយកជីវិតរបស់ ប៊ីនឡាដេន នៅតែមិនបាន ។

**ស្នាដៃកងកម្លាំងពិសេសអាមេរិកាំង :**

ក្នុងសេចក្តីរាយការណ៍ដំបូង ដែលគេពុំទានបញ្ចេញរូបខ្មោច ប៊ីនឡាដេន នៅឡើយបាននិយាយថា កងម្លាំងប្រមាណ ១៥នាក់ បានចូលទៅធ្វើប្រតិបត្តិការណ៍កុម្មង់ដូរយៈពេល៤០នាទី នៅក្នុងបរិវេណដីដ៏ធំមួយ ហ៊ុំព័ទ្ធទៅដោយជញ្ជាំងខ្ពស់ព័ទ្ធជុំវិញអាគារដ៏ស្កុកស្កមមួយ សង់នៅខាងជើងអ៊ីស្លាមបាត ។ ប៊ីនឡាដេន មានបំណងតបតមិនគ្របល់ខ្លួននាពេលរាត្រីដែលកងកម្លាំងវាយឆ្មក់ចូលមកដល់រួចជាស្រេច បានត្រូវកងឆ្មក់បាញ់សម្លាប់ បើទោះជា ប៊ីនឡាដេន យកស្ត្រីម្នាក់មកពាំងគ្រាប់កាំភ្លើងឱ្យស្លាប់ជួសក៏ដោយ អ្នកការពារម្នាក់ទំនងជាកូនរបស់ ប៊ីនឡាដេន ក៏ត្រូវសម្លាប់ ស្ត្រីពីរនាក់ទៀតបានរងរបួស ។





**ប៊ីនឡាដេន ជានរណា?**

ប៊ីនឡាដេន ជាកូនអ្នកមានសម្បត្តិមួយរូប កើតនៅឆ្នាំ១៩៥៧ នៅ ជេដា ។ គេគឺជាកូនទី១៧នៃគ្រួសារមួយដែលឪពុកមានកូន៥២នាក់ គេរៀនបានកិរិតវិស្វករស៊ីវិល ហើយចូលចលនាមូយ៉ាឌីន ឆ្នាំ១៩៧៩ ដើម្បីច្បាំងនឹងសូវៀត នៅអាហ្វគ្គានីស្ថាន ។ ចម្បាំងនេះ ប៊ីនឡាដេន បានតស៊ូយ៉ាងស្វិតស្វាញរហូតដល់មានកាពេញចិត្តពីស.រ.អា ប្រធានាធិបតីរ៉េហ្គាន ហៅ ប៊ិនឡាដិន និងក្រុមមូយ៉ាឌីន ថាជា "អ្នកច្បាំងដើម្បីសេរីភាព" ហើយផ្តល់ជំនួយ និងបង្ហាត់ហ្វឹកហ្វឺនទៀតផង ។ ឆ្នាំ១៩៨៥ ប៊ីនឡាដេន បានពង្រីកចលនារបស់ខ្លួន បង្កើនកម្លាំងទ័ពនៅតាមព្រំប្រទល់អាហ្វគ្គានីស្ថាន និងប៉ាគីស្ថាន ដោយប្រើសម្បត្តិឪពុកជាមហាសេដ្ឋីហើយពិភពអារ៉ាប ក៏គាំទ្រក្នុងការបង្កើតមជ្ឈមណ្ឌលហាត់ហ្វឹកហ្វឺនផង ។ ឆ្នាំ១៩៨៨ ប៊ីនឡាដេន បានជួបចលនាអាល់កៃដា ឆ្នាំ១៩៨៩ ដោយសារសហភាពសូវៀតដួលរំលំ ប៊ីនឡាដេន ក៏ក្លាយទៅជាវិរៈបុរសនៃពិភពអារ៉ាប បន្តិចក្រោយមកក៏បង្ហាញសញ្ញាកាន់តែខ្លាំងប្រឆាំងនឹង ស.រ.អា ដើម្បីអាល់កៃដា ដូចជា ការដាក់គ្រាប់ផ្ទុះនៅ World Trade Center ឆ្នាំ១៩៩៥ ខែកុម្ភៈ ដូចជា ការវាយប្រហារនៅខែតុលា ឆ្នាំ១៩៩៣ ធ្វើឱ្យអាមេរិកាំងស្លាប់១៨នាក់ នៅម៉ូហ្គាឌីស៊ូ និងនៅក្រោយបង្អស់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ក្រុមភេរវកម្ម១៩រូប បានបូជាជីវិតដើម្បី អាល់កៃដា តែ ប៊ីនឡាដេន ដែលបានធ្វើ ឱ្យមនុស្សស្លាប់ចំនួន២៩៧៤នាក់នៅសហរដ្ឋអាមេរិក ជននេះក៏បានក្លាយជាសត្រូវស្លាប់រស់របស់សហរដ្ឋអាមេរិក ពីថ្ងៃបើកយន្តហោះបុកអាគារភ្លោះ និងបញ្ចកោណនោះមក ។

(តមកពីលេខមុន)

**អបអរសាទរ ប៊ីនឡាដេន ស្លាប់ :**

សហរដ្ឋអាមេរិកជាពិសេស បានទទួលដំណឹងនេះប្រកបដោយអំណររីករាយ និងប្រកបដោយក្តីសង្ឃឹមថា អនាគតល្អនឹងត្រឡប់មកវិញឆាប់ៗនេះហើយ ។ នៅឯកម្ពុជាឯណោះ ក៏បានមនុស្សចូលរួមយ៉ាងកកកុញ រីករាយនឹងការស្លាប់របស់ភេរវកម្មនេះដែរ ។ ក៏ប៉ុន្តែគេពុំទាន់ឃើញសញ្ញានៃការប៉ងធ្វើការសងសឹងរបស់ភេរវករ ដែលស្រឡាញ់ ប៊ីនឡាដេន មកលើជនស៊ីវិលអាមេរិកាំងនោះនៅឡើយទេ ក្រៅពីនោះគេឃើញមានការប្រុងប្រយ័ត្នកំរិតខ្ពស់របស់ប៉ូលីសអាមេរិកាំង កុំឱ្យការសឹងសឹកអាចកើតឡើងបាន ៕

---

**កំណាព្យមិត្តអ្នកអាន**
**(បទពាក្យ ៧)**

## សួស្តីឆ្នាំថ្មីសិរីមង្គល !...

សួស្តីឆ្នាំថ្មីជ័យជយា
ឧបទ្រពចង្រៃអន្តរាយោ
ឆ្នាំថ្មីចិត្តថ្មីខន្តីធម៌
សូន្យសោះអស់ខ្វល់វល់សាមាន្យ
ធ្វើបុណ្យធ្វើទានមានមេត្តា
ទទឹងទាស់ទែងក្រែងបាត់យស
គោរពមាតាមាត្រាច្បាប់
លះបង់ចិត្តបាបកុំរែកពន់
យកពាក្យម៉ែឪគ្រូបាធ្យាយ
ជាត្រីវិស័យថ្មៃនិទស្សន៍
ស្រោចទឹកស្រង់ព្រះជម្រះផង់
សច្ចាក្នុងចិត្តចង់បានល្អ
ឆ្នាំថ្មីប្រុសស្រីផងទាំងឡាយ
អប់រំកូនចៅឱ្យខំរៀន
កាមរាគស្រើបស្រាលក្រាលក្រាស់ក្រៃ
គួរគិតកាត់ផ្តាច់ផ្តើមថែធួន
រៀបចំបោសច្រាសផ្ទះសំបែង
ទៀនធូ ផ្លែឈើមានម្លូស្លា
អាយុ វណ្ណៈ សុខៈ ពលៈ
ជួបជុំកូនចៅផៅរៀងអាយ
សូមជួយគាំពារ រក្សាថែ
ទមិឡខ្មាំងសត្រូវអន្សត្រិយ

ស្រីមង្គលាមហាតេជោ
នាំមកសុខោដល់សន្តាន ។
សិរីបវរសាយសព្វប្រាណ
គ្រប់ប្រាណប្រិមប្រិយរាសីខ្ពស់ ។
ស្តាប់លោកទេសនាស្មាលាឈ្មោះ
ជួបជួយសង្គ្រោះទុគ៌តជន ។
ត្រូវស្តាប់ត្រងត្រាប់អ្នកមានគុណ
ព្រៀងលានិរៈគន់អសោចឈ្មោះ ។
និងពាក្យតាយាយគ្រាន់ពិគ្រោះ
ក្តីមោះទ្រគោះកុំបង្ក ។
លំអុតឱនផ្ទង់ស្មោះស
ជាតិក្រោយលែងក្រជួបធនធាន ។
ចូរជៀសឱ្យឆ្ងាយពីគ្រឿងញៀន
ខំរកទើបមានទ្រព្យជាប់ខ្លួន ។
ឆ្លងរោគប្រល័យជាប់ផ្ទួនៗ
សុខភាពមាំមួនមុខមាត់ថ្លា ។
ដាក់តុតុបតែងតាំងភ្ញីផ្កា
ទឹកកា ទឹកអប់គ្រប់គ្រឿងថ្វាយ ។
ខ្មែរគ្រប់ជាន់ថ្នាក់សុខសប្បាយ
តែងកាយទទួលទេព្តាថ្មី ។
សូមជាតិខ្មែរជួបសុខសួស្តី
ដែលបួនទឹកដីឱ្យវិនាសហោង ៕

*លោក អ៊ុក សៅបុល*
*នៅទីក្រុងលីន. ម៉ាស្សាឈូសិត្តស៍*




# អាថ៌កំបាំង និងសិល្បៈនៃជីវិត
# SECRET AND ART OF LIVING



(តមកពីលេខមុន)

រៀបរៀងដោយ
លោក ម៉ៅ ច័ន្ទសំណុំ

●ពីមុនការហាត់សមាធិ វាជាបញ្ហាដាច់ខាត ព្រោះអ្នកដើរតួជាគំនិតនោះៗ ។ ឧទាហរណ៍មួយទៀត បើកំហឹងលេចឡើង អ្នកត្រូវមានសតិដឹងថា នេះជាបាតុភូតខាងក្រៅប៉ុណ្ណោះ ពោលគឺវាជាការឆ្លុះបញ្ចាំងពីម៉េមីរីមកប៉ុណ្ណោះ ។ យើងឈប់ដើរតួជាកំហឹងនោះទៀត ។ យើងមាននាទីត្រឹមតែពិនិត្យ និងព្រលែងវាទៅចុះជាការស្រេច ញ៉ាំបន្តជាប់ស្អិតនឹងកំហឹងដូចទម្លាប់មុនៗទៀត) ។ បើធ្វើដូច្នេះបាន អ្នកនឹងឈានទៅដល់ការបណ្តុះទម្លាប់ថ្មី ដែលមានអានុភាពអស្ចារ្យ ដែលជាឱសថទិព្វក្នុងដំណើរកែប្រែរបៀបរស់នៅ (Transformation of life itself ) សំដៅដណ្តើមសិទ្ធិសេរីភាព ការកាន់កាប់វាសនាដោយខ្លួនឯង និងសំរេចនូវសុភមង្គលក្នុងជីវិតជាមនុស្សនេះ ។

* **គោលការណ៍ស្រាវជ្រាវយ៉ាងល្អិតល្អន់ Investigation**

បើអ្នកសំរេចបានគោលការណ៍ ទីមួយ -ការទទួលស្គាល់ ការមានសតិដឹង (Recognition) ទីពីរ-ការព្រមទទួលយក ការសុខចិត្ត (Acceptance) ទីបី -ការពុំដើរតួ (Non-identification) អ្នកអាចនឹងឈានទៅអនុវត្តគោលការណ៍ទីបួននេះបាន ពោលគឺអ្នកមានសមត្ថភាពស្រាវជ្រាវ និងពិនិត្យល្អិតល្អន់ខាងក្នុងខ្លួនអ្នក រួមមានរូបកាយព្រមទាំងពិភពចិត្តទាំងមូល ។ ពេលនេះអ្នកតាំងខ្លួនជាអ្នកវិទ្យាសាស្ត្រដែលមានភារកិច្ចពិនិត្យស្រាវជ្រាវ និងស្វែងយល់អំពីខ្លួនឯងផ្ទាល់ (Self-study) ។ ខ្លួនឯងតែម្នាក់ដើរតួជាអ្នកពិនិត្យសិក្សាផង និងជាកម្មវត្ថុនៃការសិក្សាផង ។ ការពិនិត្យត្រូវធ្វើដោយពុំលំអៀង (Objectiveness) - ពុំមានការប្រៀបធៀបតាមគំនិតផ្ទាល់ (No comparison from your personal view) - ពុំមានបញ្ចូលការវិនិច្ឆ័យផ្ទាល់ខ្លួន (No personal Judgment) ប្រកាន់តួនាទីដូចអ្នកវិទ្យាសាស្ត្រឃើញអ្វីថាដូច្នោះ ពុំបញ្ចូលគំនិតខ្លួនទៅក្នុងនោះឡើយ ។ ជាក់ស្តែងបើកំហឹងលេចឡើងអ្នកពុំត្រូវពិចារណាថា ហេតុអ្វីបានជាខឹងអ្នកមាននាទីត្រឹមតែដឹងថាមានកំហឹងកំពុងកើតមានក្នុងអាត្មាអញហើយ ចប់ត្រឹមនោះ (You just know, just aware the fact, that's it ). បើមានគំនិតណាផុះឡើងហើយ អ្នកគ្រាន់តែដឹងថាមានគំនិតមួយកើតឡើងហើយប៉ុណ្ណោះ ពុំពិចារណាឡើយ ។ ឥរិយាបថនេះ អាចប្រៀបធៀបទៅនឹងរូបភាព ដបធំមួយសំរាប់ដាក់សម្ភារៈផ្សេងៗ ។ ដបតែមួយ គេអាចដាក់របស់ច្រើនយ៉ាង គេអាចដាក់ ទឹក ប្រេង មាស ឬលុយ ។ល។ ពេលនេះខ្លួនយើង ឬសតិយើងដើរតួដូចជាដបនេះដូច្នោះឯង ។ យើងជាតួដបនេះពុំមែនអ្វីៗដែលនៅក្នុងដបនោះឡើយ ( We are the bottle itself , We are not the content ) ។ ខ្ញុំសូមលើកការប្រៀបធៀបមួយទៀត « មេឃ និងពពក » ។ មេឃធំទូលំទូលាយ នៅនឹង ពុំកំរើក ពុំមានសកម្មភាពអ្វីឡើយ ដោយឡែកពពកលេចឡើងហើយរលាយបាត់ទៅ លេចឡើងហើយរលាយបាត់ទៅពុំចេះដាច់ឡើយ ។ សតិយើងប្រៀបដូចជាមេឃនេះ ចំណែកឯកំហឹងលំហូរគំនិតប្រៀបដូចជាពពកនោះៗដូច្នោះឯង ។

ការពិនិត្យស្រាវជ្រាវល្អិតល្អន់នេះ ត្រូវធ្វើលើមុខសញ្ញាទីមួយលើរូបកាយ ទីពីរលើពិភពផ្លូវចិត្ត ។

ទីមួយលើរូបកាយ : ពិនិត្យវេទនាលើរូបកាយ (Body sensation) តើមានអ្វីខ្លះ ? ដូចជា ការស្ពឹក ការញាប់ញ័រ ការឈឺចាប់ ភាពតឹង ស្រពន់ សម្លេងបេះដូង សម្លេងដឹបចរ ចលនាដកដង្ហើម ក្តៅ ត្រជាក់ រងា ចំហាយ ។ល។ បើអ្នកអាចធ្វើដូច្នេះបាន អ្នកប្រាកដជារកឃើញឧបករណ៍មួយដ៏អស្ចារ្យ ពោលគឺអ្នកត្រូវបានរួចរំដោះចាកចេញពីការក្បៀបសង្កត់នៃបន្ទប់ម៉េម៉ូរី ដោយងាយ (អ្នកឯករាជ្យពីខ្សែញាក់របស់ម៉េម៉ូរី) ឬនិយាយម្យ៉ាងទៀតគឺថា អ្នកអាចសំរាកសំរួលបន្ធូរភាពតឹងតែងក្នុងរូបកាយបានប្រសិទ្ធិភាពអស្ចារ្យណាស់ (Watching your body sensation allows you to relax completely from the influence of your mental movement ។ your thoughts, emotions, feelings, memories) ។ សូមបញ្ជាក់ថា អ្នកពុំអាចពិចារណាឃើញ (តាមខួរក្បាល) នូវបាតុភូតដ៏អស្ចារ្យ ដូចខ្ញុំរៀបរាប់ខាងលើនេះឡើយ មានតែការពិសោធន៍ជាក់ស្តែងប៉ុណ្ណោះ ទើបអាចយល់ដឹងឬជ្រួតជ្រាបបាន ។

ទីពីរការពិនិត្យលើពិភពផ្លូវចិត្តទាំងមូល : ការពិនិត្យស្រាវជ្រាវផ្លូវចិត្ត ត្រូវប្រព្រឹត្តទៅដោយពុំលំអៀងដូចន័យខាងលើស្រាប់ ។ មុខសញ្ញាមានដូចជា លំហូរគំនិត អារម្មណ៍ ការរំជួលចិត្ត ប្រតិកម្ម ការស្រមៃ ម៉េម៉ូរី ។ល។ បាតុភូតផ្លូវចិត្តទាំងអស់នេះ បើអ្នកអាចពិនិត្យដោយគ្មានលំអៀងបាន មានន័យថា អ្នកអាច ផ្តាច់ខ្លួនអំពីចរន្ត បាតុភូត ទាំងអស់នោះហើយ ។

ជាក់ស្តែង បើអ្នកអាចពិនិត្យមើលការផុះឡើងនៃលំហូរគំនិតអ្នកលែងដើរតួជាគំនិតទាំងនោះទៀតហើយ អ្នកព្រលែងគំនិតនោះៗឱ្យហូរចូលមកលំហផ្ទៃលើនៃចិត្តដោយសេរី ពុំទប់ពុំឃាត់ឃាំង ។ គំនិតមួយលេចមក ហើយរលាយបាត់ទៅគំនិតមួយទៀតលេចឡើង ហើយរលាយបាត់ទៅទៀត ហូរហែជាបន្តបន្ទាប់មិនដាច់ ។ គំនិតទាំងនោះគ្រាន់តែជាការផ្តល់យោបល់ ពុំមែនបញ្ជាមកលើយើងដូចទម្លាប់មុនៗឡើយ ។ តាមរបៀបនេះ អ្នកអាចមានសមត្ថភាពសំអាតបន្ទប់គិតបានប្រសើរជាងមុន ។ មានន័យម្យ៉ាងទៀត បើការគិតនោះមានសភាពល្អក់ខ្វល់រកច្រកចេញពុំរួច វិធីដូចជំរាបខាងលើនេះ អាចឱ្យអ្នករកឃើញគំនិតថ្មីៗថែមទៀត ព្រោះអ្នកឈប់ជាប់ស្អិតនឹងគំនិតណាមួយដោយឡែក ហើយគំនិតណាមានប្រយោជន៍ ទើបអ្នកជ្រើសរើសចាប់ទុកប្រើ ។ ខ្ញុំអាចប្រៀបធៀបអ្នកដូចជាលំហមេឃធំល្វឹងល្វើយ ចំណែកគំនិតនានាដូចជាដុំពពកនានាដែលបណ្តែតខ្លួនរសាត់ក្នុងលំហនោះប៉ុណ្ណោះ ។

(តទៅលេខក្រោយទៀត)






ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី២៩ ខែមេសា ឆ្នាំ២០១១

# Cease-Fire Halts Seven Days of Border Fighting

By Phann Ana and Tim Sturrock
THE CAMBODIA DAILY

Cambodian and Thai officials declared a cease-fire yesterday on a seventh day of fighting at the Thai-Cambodian border, the longest stretch of violence since armed border conflict first erupted in 2008.

Related story, see page 23

Major General Chea Morn, commander of RCAF Region 4, and Lieutenant General Thawatchai Samutsakorn, commander of Thailand's Army Region 2, reached the agreement after a meeting of more than 90 minutes that followed heavy shelling near Ta Moan and Ta Krabei temples in Oddar Meanchey province, according to statements yesterday from the Defense Ministry.

Under the cease-fire, the fighting must stop, troops must refrain from mobilizing and commanders are encouraged to form special teams to improve communications, a statement said. The two sides must also facilitate the return of civilians to their homes and reopen any border checkpoints.

The statement also acknowledged the limitations of the meeting and the long road ahead in the conflict: "Let the Joint Boundary Committee from the two governments solve the border dispute. The military can only solve problems related to the cease-fire."

Indonesian Foreign Ministry spokesman, Michael Tene, said that Foreign Minister Marty Natalegawa met with Thai Foreign Minister Kasit Piromya yesterday in Jakarta, where the latter affirmed Thailand's commitment to a cease-fire, a peaceful resolution and the role of Asean in the matter.

"Of course, it is our understanding that the position of Thailand on these basic issues is in line with the position of Cambodia, and therefore, on paper at least, Thailand and Cambodia are committed to a diplomatic solution to their problem," he said.

He said Thailand and Cambodia were close to finalizing an agreement to bring Indonesian observers to the area, but he declined to provide details. Cambodia and Thailand have disagreed on whether observers would be allowed in the 4.6-square-kilometer disputed area at Preah Vihear temple.

The two ministers discussed the possibility of bilateral talks with "appropriate engagement" by Indonesia, Mr Tene said.

Defense Ministry spokesman Lieutenant General Chhum Sucheat declined to comment, and Thai Foreign Ministry spokesmen for the Thai and Cambodian foreign ministries could not be reached.

In an article posted on the Bangkok Post website, Royal Thai Army Commander General Prayuth Chan-ocha was cited as casting doubt on the strength of the cease-fire agreement.

"Actually, a cease-fire has begun. Unit commanders of the two sides in the area had talks to end the fighting. Let's wait and see whether there will be more fighting this afternoon, tonight and tomorrow."

A senior RCAF official on the front line, who spoke on condition of anonymity, expressed similar views that the cease-fire might not last.

"The situation in general is looking better, but we still cannot trust them," the lieutenant colonel said. "If we withdrew our forces, they would promptly shoot us again."

A statement yesterday from the Defense Ministry detailed the intense fighting that preceded the agreement.

Thai forces attacked Cambodian positions near Ta Moan and Ta Kabrei temples with heavy artillery on Wednesday night, and shelling continued until 3:55 am yesterday morning, according to the statement. Thailand also shelled near another pagoda in Banteay Ampil district. Shelling later resumed on RCAF positions west of O'Smach district.

Thailand has long supported bilateral talks, with Cambodia supporting a third party because it says Thailand has broken past bilateral agreements.



Neou Vannarin/The Cambodia Daily
Soldiers from the Prime Minister Bodyguard Unit prepare tents yesterday in Oddar Meanchey province's Chongkal district for civilians displaced by the recent border fighting. Officials plan to send refugees there from the nine current camps set up in and around Samroong City.

# សម្រេចបានបទឈប់បាញ់គ្នាមួយបន្ទាប់ពីការផ្ទុះអាវុធរយៈពេលពេល៧ថ្ងៃនៅតំបន់ព្រំដែន

ដោយ : ផាន់ អាណា និង Tim Sturrock
THE CAMBODIA DAILY

ក្រុមមន្ត្រីកម្ពុជា និងក្រុមមន្ត្រីថៃ បានប្រកាសនូវបទឈប់បាញ់មួយកាលពីម្សិលមិញនៅថ្ងៃទី៧នៃការប្រយុទ្ធគ្នានៅតំបន់ព្រំដែនកម្ពុជាថៃ ដែលជាការប៉ះទង្គិចគ្នាមានរយៈពេលយូរបំផុតចាប់តាំងពីជម្លោះប្រដាប់អាវុធនៅតាមព្រំដែនបានផ្ទុះឡើងជាលើកដំបូងកាលពីឆ្នាំ២០០៨ ។

លោកឧត្តមសេនីយ៍ទោ ជា ម៉ន ជាមេបញ្ជាការយោធាភូមិភាគ៤នៃកងយោធពលខេមរភូមិន្ទ និងលោកឧត្តមសេនីយ៍ឯក ថាវ៉ាត់ឆៃ សាមុតសាខន ជាមេបញ្ជាការយោធាភូមិភាគ២ថៃបានសម្រេចកិច្ចព្រមព្រៀងមួយ បន្ទាប់ពីជំនួបអស់រយៈពេលជាង ៩០នាទី ដែលធ្វើឡើងបន្ទាប់ពីមានការផ្លោងគ្រាប់ដ៏ខ្លាំងនៅក្បែរប្រាសាទតាមាន់ និងប្រាសាទតាក្របីក្នុងខេត្តឧត្តរមានជ័យនេះ បើតាមសេចក្តី ថ្លែងការណ៍កាលពីម្សិលមិញរបស់ក្រសួងការពារជាតិ ។

សេចក្តីថ្លែងការណ៍នេះបានលើកឡើងថា បទឈប់បាញ់នេះចែងថា ត្រូវបញ្ឈប់ការបាញ់គ្នា មិនត្រូវចល័តកម្លាំង ហើយជំរុញឱ្យមេបញ្ជាការជួរមុខបង្កើតក្រុមការងារពិសេសដើម្បីធ្វើឱ្យការទំនាក់ទំនងកាន់តែប្រសើរឡើង ។

ភាគីទាំងពីរក៏ត្រូវបង្កលក្ខណៈងាយស្រួលឱ្យជនស៊ីវិលវិលត្រឡប់ទៅផ្ទះសម្បែងរបស់ខ្លួន និងបើកច្រកព្រំដែនឡើងវិញ ។

សេចក្តីថ្លែងការណ៍នេះក៏បានទទួលស្គាល់ផងដែរ ពីកម្រិតនៃជំនួបនេះនិងដំណើរការដ៏វែងឆ្ងាយទៅមុខទៀតនៅក្នុងជម្លោះនេះដោយលើកឡើងថា "ទុកលទ្ធភាពឱ្យគណៈកម្មាធិការព្រំដែនរួមរបស់រដ្ឋាភិបាលទាំងពីរធ្វើការដោះស្រាយជម្លោះព្រំដែន។ យោធាអាចត្រឹមតែដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងបទឈប់បាញ់គ្នាប៉ុណ្ណោះ ។

លោក Michael Tene ជាអ្នកនាំពាក្យក្រសួងការបរទេសឥណ្ឌូនេស៊ីបានមានប្រសាសន៍ថា លោក ម៉ាទី ណាតាឡេហ្គាវ៉ា ជារដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី បានជួបជាមួយលោក កាស៊ីត ភិរម្យ រដ្ឋមន្ត្រីការបរទេសថៃកាលពីម្សិលមិញនៅក្នុងទីក្រុងហ្សាការតា ទីដែលលោក កាស៊ីត បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ប្រទេសថៃចំពោះការមានបទឈប់បាញ់ ដំណោះស្រាយសន្តិវិធី និងតួនាទីរបស់អាស៊ាននៅក្នុងជម្លោះនេះ ។

លោកបានមានប្រសាសន៍ថា "ប្រាកដណាស់ វាគឺជាការយល់ឃើញរបស់យើងដែលថា ជំហររបស់ថៃស្តីពីបញ្ហាទាំងនេះគឺស្របទៅនឹងជំហររបស់ប្រទេសកម្ពុជាដែរ ។ យ៉ាងហោចណាស់ក៏ជាគោលការណ៍ប្រទេសថៃ និងប្រទេសកម្ពុជាប្រកាន់យកដំណោះស្រាយការទូតដើម្បីដោះស្រាយបញ្ហារបស់ខ្លួន ។

លោកបានមានប្រសាសន៍ថា ប្រទេសថៃ និងប្រទេសកម្ពុជាជិតសម្រេចបានកិច្ចព្រមព្រៀងមួយដែលនឹងឈានដល់ការបញ្ជូនក្រុមអ្នកសង្កេតការណ៍ឥណ្ឌូនេស៊ីមកកាន់តំបន់នោះហើយ ប៉ុន្តែលោកបាន បដិសេធមិនផ្តល់ព័ត៌មានលំអិត ។

ប្រទេសកម្ពុជា និងប្រទេសថៃ បានខ្វែងគំនិតគ្នាជុំវិញថា តើត្រូវអនុញ្ញាតឱ្យក្រុមអ្នកសង្កេតការណ៍ទាំងនេះឈរជើងនៅតំបន់មានជម្លោះទំហំ៤.៦គីឡូម៉ែត្រការ៉េក្បែរប្រាសាទព្រះវិហារឬយ៉ាងណា ។

លោក Tene បានមានប្រសាសន៍ថា រដ្ឋមន្ត្រីទាំងពីរបានពិភាក្សាពីលទ្ធភាពនៃការចរចាទ្វេភាគី ដោយមាន "ការចូលរួមដ៏សមស្រប" ពីឥណ្ឌូនេស៊ី។

លោកឧត្តមសេនីយ៍ឯក ឈុំ សុជាតិ អ្នកនាំពាក្យក្រសួងការពារជាតិបានបដិសេធមិនធ្វើអត្ថាធិប្បាយ ហើយគេមិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការបរទេសថៃ និងអ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាបានទេ ។

អត្ថបទមួយដែលចុះផ្សាយនៅលើវិបសាយរបស់កាសែតបាងកកប៉ុស្តិ៍បានឱ្យដឹងថា លោកឧត្តមសេនីយ៍ ប្រាយុទ្ធ ចាន់អូចា ជាអគ្គមេបញ្ជាការកងទ័ពថៃបានសម្តែងមន្ទិលពីភាពរឹងមាំនៃកិច្ចព្រមព្រៀងឈប់បាញ់នេះ ។

លោកត្រូវបានដកស្រង់សម្តីយ៉ាងដូច្នេះថា "ពិតណាស់ បទឈប់បាញ់បានចាប់ផ្តើមហើយ ។ មេបញ្ជាការនៃភាគីទាំងពីរប្រចាំតំបន់បានចរចាគ្នា ដើម្បីបញ្ចប់ការផ្ទុះអាវុធ ។ ចាំមើលៗតើនឹងមាន ការប្រយុទ្ធគ្នាបន្តទៀតនៅរសៀលថ្ងៃនេះ យប់នេះ និងថ្ងៃស្អែកឬទេ"។

មន្ត្រីជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទមួយរូបនៅខ្សែត្រៀមជួរមុខដែលសុំមិនបញ្ចេញឈ្មោះបានបញ្ចេញទស្សនៈស្រដៀងគ្នានេះថា បទឈប់បាញ់នេះប្រហែលជាមិនយូរអង្វែរទេ។

វរសេនីយ៍ទោរូបនេះបាននិយាយថា "ស្ថានភាពទូទៅហាក់ដូចជាប្រសើរជាងមុនមែន ប៉ុន្តែយើងនៅតែមិនទុកចិត្តពួកគេ ។ ប្រសិនបើយើងដកកងទ័ពរបស់យើង ពួកគេនឹងបាញ់ពួកយើងម្តងទៀតភ្លាម" ។

សេចក្តីថ្លែងការណ៍កាលពីម្សិលមិញរបស់ក្រសួងការពារជាតិបានលំអិតអំពីការប្រយុទ្ធគ្នាដ៏ខ្លាំងដែលកើតមានមុនកិច្ចព្រមព្រៀងនេះ ។

យោងតាមសេចក្តីថ្លែងការណ៍នេះបានឱ្យដឹងថា កងទ័ពថៃបានវាយមកលើទីតាំងឈរជើងរបស់កងទ័ពកម្ពុជាក្បែរប្រាសាទតាមាន់ និងប្រាសាទតាក្របីដោយបាញ់កាំភ្លើងធំធ្ងន់កាលពីយប់ថ្ងៃពុធ ហើយការបាញ់ផ្លោងបានបន្តរហូតដល់ម៉ោង៣:៥៥នាទីទៀបភ្លឺឈានចូលព្រឹកថ្ងៃព្រហស្បតិ៍ ។

ថៃក៏បានផ្លោងគ្រប់ផ្លោងក្បែរវត្តមួយទៀតនៅក្នុងស្រុកបន្ទាយអំពិលផងដែរ ។ ក្រោយមកបន្តបាញ់ផ្លោងមកលើទីតាំងឈរជើងរបស់កងយោធពលខេមរភូមិន្ទនៅឯភាគខាងលិចស្រុកអូរស្មាច់ និងបន្តនៅឡើយគិតត្រឹមម៉ោង៨ព្រឹក ។

ទោះបីជាភាពតានតឹងបានធូរស្រាលបន្តិចក៏ដោយ ក៏គេនៅមិនប្រាកដថា តើចំណាត់ការរបស់ប្រទេសទាំងពីរជាអ្វីនោះទេ ដោយប្រទេសទាំងពីរខ្វែងគំនិតគ្នាម្តងហើយម្តងទៀតជុំវិញលក្ខខណ្ឌជាមូលដ្ឋាននៃការចរចារបស់ខ្លួន ។

ប្រទេសកម្ពុជាបានគាំទ្រកិច្ចចរចាទ្វេភាគីជាវៀងរហូតមក ចំណែកប្រទេសកម្ពុជាគាំទ្រឱ្យមានភាគីទី៣ចូលរួម ពីព្រោះខ្លួនលើកឡើងថា ប្រទេសថៃបានរំលោភកិច្ចព្រមព្រៀងទ្វេភាគីនានាកន្លងមក។

កាលពីថ្ងៃអង្គារលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវឱ្យមានបទឈប់បាញ់គ្នាមួយ ហើយបានមានប្រសាសន៍ថា លោកមានគម្រោងពិភាក្សាបញ្ហានេះនៅក្នុងជំនួបកំពូលអាស៊ាននៅខែ មិថុនាក្នុងក្រុងហ្សាការតា ។

វិបសាយរបស់កាសែតបាងកកប៉ុស្តិ៍បានរាយការណ៍កាលពីម្សិលមិញថា ប្រសិនបើការប្រយុទ្ធគ្នា បានបញ្ឈប់មែនឧត្តមសេនីយ៍ ប្រាវីត វង់សូវ៉ាន់ ជារដ្ឋមន្ត្រីការពារជាតិថៃគ្រោងនឹងជួបជាមួយលោកឧត្តមសេនីយ៍ ទៀ បាញ់ ជាសមភាគីកម្ពុជារបស់លោកនៅពេលណាមួយបន្ទាប់ពីថ្ងៃសៅរ៍ នេះបើតាមការលើកឡើងរបស់ឧត្តមសេនីយ៍ ណុបប៉ាដុន អ៊ីនថាប៉ាន់យ៉ា ជាលេខាធិការរបស់លោកឧត្តមសេនីយ៍ ប្រាវីត ៕

# GEM MINE JEWELRY CO

*Diamond & Fine Jewelry*



Gem Stones – Fine Watches –
Custom Design 14K-18K – Platinum
Repair Done on Premises
108 S 8th St
Philadelphia, PA 19107
Neighborhood: Market East

**(215) 928-8108**

# Vihi Insurance-Income Tax Mortgage-Realty

**ធានារ៉ាប់រង_តាក់លើប្រាក់ចំណូល_ខ្ចីប្រាក់ទិញផ្ទះ_ទិញលក់ផ្ទះ**

**Insurance** **ធានារ៉ាប់រង**
(Licensed PA, NJ & DE) អាជ្ញាប័ណ្ណ PA, NJ & DE
Home • ផ្ទះ Car • រថយន្ត
Business • មុខរបរ Health • សុខភាព

**Income Tax** **តាក់លើប្រាក់ចំណូល**
Individual • ផ្ទាល់ខ្លួន Business • ពីមុខរបរ
Pay Roll • ពីប្រាក់ខែ
Forming New Business • បង្កើតមុខជំនួញថ្មី
Home Deed Transfer • ប្តូរឈ្មោះផ្ទះ
Auto Title Transfer • ប្តូរឈ្មោះម្ចាស់រថយន្ត




**Vihi Mortgage Vihi ខ្ចីប្រាក់ទិញផ្ទះ**

| | |
|---|---|
| (Licensed by PA Dept. of Banking) | • អាជ្ញាប័ណ្ណពី PA ការិយាល័យធានាគារ |
| Hiep Vo, MBA, President. | • ហ៊ីប វ៉ូ MBA ប្រធាន |
| Finance/Refinance your home | • ផ្តល់ប្រាក់កម្ចីក្នុងការទិញផ្ទះទិញដំបូង ឬកណ្តាលទី |
| Low interest Rate & Down Payment | • ការប្រាក់ថោក និងលុយកក់តិច |
| Fast Preapproval | • ចម្លើយលឿន |

**Vihi Realty Co**
Dr. Hanh Vo, Broker/Owner Cell (267) 664-2689
Buy & Sell Properties & Businesses
Visit: www.drhanh.net for more foreclosure homes

**North Phila – 215-276-8441**
**5225 N. 5th Street**
**Phila., Pa 19120**

**South Phila – 215-336-0600**
**1519 W. Passyunk Ave.**
**Phila., Pa 19145**
**www.vihifinancial.com**

# ត្រូវការការងារ ? ត្រូវការគុណប្រយោជន៍ល្អ ?

*ឆក់យកឱកាសនឹងកម្មវិធីដែល* **Penn Asian Senior Services** *មាន:*



Penn Asian Senior Services
PASSi
*For a better life at home*

**ធ្វើជាអ្នកជំនួយថែរក្សាសុខភាពនៅផ្ទះ** (Home Health Aide) :
* ការហ្វឹកហ្វឺនតំលៃ 4១000 នឹងផ្តល់ជូនអោយកូនសិស្សដោយឥតគិតថ្លៃ
* ពេលវេលាហ្វឹកហ្វឺនតែ ៨០ ម៉ោងប៉ុណ្ណោះ ហើយអាចផ្លាស់ប្តូរបាន
* ថ្នាក់រៀនចាប់ផ្តើមនៅក្នុងនិទាឃរដូវ (រដូវផ្ការីក) ឆ្នាំ ២០១១ នេះ
* ថ្នាក់រៀននឹងជួបគ្នានៅ Asian Arts Initiative, Chinatown

**ធ្វើជាអ្នកជំនួយការគិលានុបដ្ឋា** Certified Nursing Assistant (CNA):
**កម្មវិធីជំនួយគិលានុបដ្ឋានៅក្នុងនិទាឃរដូវ (រដូវផ្ការីក) និងរដូវក្តៅឆ្នាំ ២០១១**
* មានជំនួយក្នុងថ្លៃសាលា
* រួមទាំងឯកសណ្ឋាន ផ្លាកអត្តសញ្ញាណប័ណ្ណ និងសៀវភៅមេរៀន !
* កម្មវិធីមានរយះពេល ៦ អាទិត្យកន្លះ ( ការហ្វឹកហ្វឺនចំនួន ១២០ ម៉ោង)
* ថ្នាក់រៀនជាភាសាអង់គ្លេស
* ការហ្វឹកហ្វឺនចាប់ផ្តើមនៅក្នុងនិទាឃរដូវ (រដូវផ្ការីក) ,រដូវក្តៅឆ្នាំ ២០១១
* ថ្នាក់រៀនតែក្នុងពេលល្ងាច មានពី( ម៉ោង៥:00 ដល់ ម៉ោង៩:00)
* ថ្នាក់គ្លីនិកមានក្នុងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យនៅ Rydal Park (1515 The Fairway, Rydal, PA 19046) ពីម៉ោង ៧:៣០ ព្រឹក ដល់ម៉ោង ១:៣០ រសៀល និងពីម៉ោង ៧:៣០ ល្ងាចដល់ម៉ោង ២:00 រសៀល

**តំរូវការតំរូវការ**
* ត្រូវចេះអាន សរសេរ និងនិយាយភាសាអង់គ្លេសក្នុងកំរិតថ្នាក់ទី ៦ (នឹងមានធ្វើការវាយតំលៃផ្នែកភាសាអង់គ្លេស)
* មានសញ្ញាប័ត្រមធ្យមសិក្សា ឬ សញ្ញាប័ត្រ GED ក៏មានអាទិភាព ប៉ុន្តែមិនទាមទារទេ
* ប្រឡង Mantoux (PPD) ពីរដំណាក់កាល
* ការពិនិត្យរាងកាយ
* ថ្លៃចុះឈ្មោះ 4900
* ប្រវត្តិរូប
* របាយការណ៍ផ្ទាល់ខ្លួន (របាយការណ៍ ២ កថាខ័ណ្ឌ សរសេរអំពីហេតុអ្វីបានជាអ្នកចង់ធ្វើជាអ្នកជំនួយការគិលានុបដ្ឋា)
* លិខិតស្នាមដែលបញ្ជាក់ថា អ្នកអាចធ្វើការនៅក្នុងសហរដ្ឋអាមេរិកបាន
* អាចឈរបានយូរ អាចលើកវត្ថុទំងន់យ៉ាងតិចណាស់ ៤០ ផោន ហើយដៃទាំងពីរអាចប្រើការបាន

**ចុះឈ្មោះនៅក្នុងថ្ងៃនេះ!** *ថ្នាក់រៀនមានកំណត់*
*ព័ត៌មានបន្ថែមសូមទូរសព្ទមកកាន់ Jenny Sanchez តាមរយៈលេខ 215.572.1234*

**រៀនភាសាអង់គ្លេស :**
* រៀនភាសាអង់គ្លេស ត្រៀមខ្លួនដើម្បីអាជីពក្នុងផ្នែកសុខាភាព
* ថ្នាក់វិជ្ជាជីវៈភាសាអង់គ្លេសជាភាសាទីពីរ Vocational English as a Second Language (VESL)
* ថ្ងៃទី ២៦ ខែមេសា ដល់ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១១

*នៅ **Penn State Abington**
រាល់ថ្ងៃអង្គារ៍ និងថ្ងៃព្រហស្បតិ៍ ពីម៉ោង ៥ ដល់ម៉ោង ៨ល្ងាច
ថ្ងៃសៅរ៍ ពីម៉ោង ៩ព្រឹក ដល់ម៉ោង ៣រសៀល
តំលៃ: $100 ថែមទាំងតំលៃសៀវភៅ ($60)

**ចុះឈ្មោះនៅក្នុងថ្ងៃនេះ!** ថ្នាក់រៀនមានកំណត់
*ព័ត៌មានបន្ថែមសូមទូរស័ព្ទមកកាន់* Jenny Sanchez តាមរយៈលេខ: 215.572.1234

Penn Asian Senior Services 420 Old York Road Jenkintown, PA 19046
ទូរស័ព្ទ: 215-572-1234
ទូរសារ:215-572-1102
គេហទំព័រ: www.passi.us
អ៊ីមែល info@passi.u

Penn Asian Senior Services
PASSi
*For a better life at home*

# Cambodian Community in Lynn, MA on the Rise

*KhmerPost USA Writer, Audria Chea*
*Photos by Sam Khoeun*

Lynn, MA - Saturday, April 30th, Khmer Cultural Planning Committee (KCPC) hosted its 10th Annual Khmer New Year Celebration and Community Fair. The event received a pouring support from the Mayor of the city, private businesses and institutions as well as Health Care facilities and agencies, among other dozens of community partnerships. Many Lynn Community Health Center employees contributed into this successful planning and event. It was estimated that nearly 1,000 people participated and marked its highest record of attendance.

The Program began by the Cambodian custom parade about one mile starting from Buddhist Temple, Wat Sanghikaram, on 110 Chestnut St. to the Common via Union St. The Mayor Judith Flanagan Kennedy of Lynn appeared at Common for the Opening Remarks and took time to say hello and wishes Festival goers a Happy Cambodian New Year

Ms. Sophor Chhour, the chairwoman for KCPC and a clinician from Lynn Community Health Center stated, "I am very happy to work in an environment where the collaboration brought together the old and the new generations of Cambodian-American born to share our culture as well as to strengthen our community leadership". There were foods from local vendors, music, cultural performance, games, health screens and resources offer to public. Sophea Neak, an '08 college grad, served as a Fundraiser Coordinator for the event shared, "together—we learned to run a community fair event on the Lynn Common required a lot of time to work with the city to obtain permits from zoning to allowing local Asian Vendors to participate." Neak said what made the event so successful was the team of volunteers.



Harry Schnur, the event co-coordinator, reported, "We have a team effort from 30 Khmer American Youth in Action (KAYA) who cleaned the Common on Friday night, set up for Saturday morning, did the cleaning throughout the event and after the event." He continued, "The secret of the success is to engage youth energy." Schnur shared the event organizing staffs were very vigilant about the safety for the public, but there was no show of safety concern and that everyone showed the respect for the day and that the city officials took a chance on KCPC to host the event on the Lynn Common.



Mr. Vong Vichet, an elderly of Lynn resident and also one of the planning committees said, "This is the first year we hosted on the Common. We have people come from Lynn, Revere, Boston, and Lowell."

The community residents appreciated such event that brings them sense of connection with culture, community, and family. "Outdoor event is always part of our culture. ***(Continued to page 14)***



# ការិយាល័យវេជ្ជបណ្ឌិត

**ខេរិន : (267) 210 7870**



ក្រុមហ៊ុនយើងមានបទពិសោធន៍
១០ឆ្នាំក្នុងការព្យាបាល :

| | |
|---|---|
| Slip & Fall | រអិល និងដួល |
| Auto Accident | គ្រោះថ្នាក់រថយន្ត |
| Back Pain | ឈឺខ្នង |
| Headache | ឈឺក្បាល |
| Neck Pain | ឈឺកញ្ចឹងក |



- មានអ្នកបកប្រែ និយាយភាសាខ្មែរ, ខេរិន TeL: (267) 210 7870
- មានការណែនាំជូន មេធាវី ដែលមានបទពិសោធន៍ច្រើនឆ្នាំ

South Office: 215-776-6215
PAIN & INJURY
CHIROPRACTIC CENTER
1100 Washington Ave., Lot C, Unit #C2
Philadelphia, PA 19147
Tel. 215-468-7256

North Office: 267-408-6150
VN Chiropractic Center
5416 N. 5th St.
Philadelphia, PA 19120
Tel. 215-324-1400



BUY RITE
267-297-5879

# PHARMACY

RITE PRICE · RITE ADVICE · WE CARE

Nhà Thuốc Tây 藥房 ឱសថស្ថាន



**We're located between Old York Rd. & Rockland St. Across from the Rockland Laundromat**

**យើងមានទីតាំងនៅចន្លោះផ្លូវ Old York Rd. និង Rockland St**

**នៅ "Buy Rite Pharmacy" យើងខ្ញុំផ្តល់នូវសេវាដូចខាងក្រោមនេះ**

-តម្លៃថោកៗបំផុត
-ការពិនិត្យ និងពិភាក្សាជាមួយស្មៀវភៅទាំងអស់
-ការទទួលស្វាគមន៍ដោយរីករាយ និងផ្តល់សេវា ដោយរហ័សទាន់ចិត្ត
-មានស្តុកប្រភេទឱសថគ្រប់មុខ
-មានឱសថវីតាមីន-ឱសថចិនសៃ និងឧបករណ៍ទាំងឡាយសម្រាប់ការព្យាបាលមុខជំងឺ
-ទទួលផ្តល់ឱសថតាមសេចក្តីត្រូវការ ( តាមវេជ្ជបញ្ជា)

ម៉ោងធ្វើការ :
ច័ន្ទ-សុក្រ : **9am-7pm**
សៅរ៍ : **9am-5pm**
អាទិត្យ : បិទទ្វារ

1337 W. Rockland St.
Philadelphia, PA 19141

**Tel: 267-297-5879**
**Fax: 267-297-5880**



John S. and James L.
**Knight Foundation**
*informed and engaged communities*

PLEASE JOIN THE CAMBODIAN ASSOCIATION OF GREATER PHILADELPHIA IN CELEBRATION OF THE OPENING OF OUR:

សូមអញ្ជើញចូលរួមជាមួយនឹងសមាគមខ្មែរតំបន់ហ្វីឡាដែលហ្វៀ ក្នុងឱកាសពិធីសម្ពោធបណ្ណាល័យមិនយកកំរៃ ដែលអនុញ្ញាតិដល់ពលរដ្ឋក្នុងតំបន់ឱ្យអាចធ្វើការទាក់ទងតាមអិនធើណេតមានកុំព្យូទ័រថ្មីៗ កម្មវិធីទំនើប និងអាចភ្ជាប់ទៅជុំវិញពិភពលោក ដោយមិនយកកំរៃ ហើយនៅក្បែរផ្ទះរបស់យើងផង ។

# FREE LIBRARY HOT SPOT

# បណ្ណាល័យឥតគិតថ្លៃដ៏ទំនើបទាន់សម័យ

MAY 18, 2011
11:30AM.

CAMBODIAN ASSOCIATION OF GREATER PHILADELPHIA 2416 57TH STREET PHILADELPHIA, PA 19148

RSVP TO RORNG@CAGP.ORG

Free LIBRARY OF community

សមាគមខ្មែរតំបន់ហ្វីឡាដែលហ្វៀ
CAMBODIAN ASSOCIATION OF GREATER PHILADELPHIA, INC.

*FREE Library Hot Spots allow Community residents to connect to the internet, use the latest computer software, and link up to the world around them all for free and right in the neighborhood*



# ភោជនីយដ្ឋាន ឆាយណាស្តារ China Star

មានម្ហូបចិន
ម្ហូបប៉ូលីណេស៊ី
ម្ហូបចិនកង់តុង
ម្ហូបម៉ង់ដារិន

Chinese -Polynesian -Cantonese -Mandarin
369 Broadway St., Lowell, MA 01854
Tel: 978-454-7578, 978-454-7507

Open Daily: Sun. to Thurs. 11:00 AM to 1:00 AM
Fri. and Sat. 11:00 AM to 3:00 AM



យើងអាចយកម្ហូបទៅដល់ផ្ទះបាន
We Deliver All Day: 11:30 AM to 1:00 AM Available to most areas. Min. $10.00 Delivery Charge $2

$17.99

បង្កងឆាខ្ញី និងខ្ទឹមពិសេស
SPECIAL 2 Lobsters w/ Scallion & Ginger



# Business For Sale
## លក់ហាងលក់គ្រឿងទេសផ្ទះនៅរីវៀ




ដើម្បីព័ត៌មានបន្ថែមសូមទាក់ទង
Hanna: 781.535.8625 ឬ
Hong : 617.780.1019
**អាសយដ្ឋាន :** អូរ៉ង់ហ្ស៍ ហ្គ្រូម៉ាកិត
**Orange Grove Market**
**(Beer, Wine, Grocery, Lottery)**
**158 Shirley Ave, Revere, MA 02151**





# NEW CHINA PEARL
## DIM SUM

288 Mishawum Rd., Woburn, MA 01801
Phone:(781) 932-0031/Fax: (781) 932-0346
www.NewChinaPearl.com
From Boston 95 South; Exit 37B, from Lowell 93 South; Exist 37B, from RT-128; Exit 36.

ភោជនីយដ្ឋានញូឆាយណាភើលសូមអញ្ជើញលោកអ្នក និងក្រុមគ្រួសារមករីករាយជាមួយម្ហូបអាហារមកពីហុងកុង និងប្រទេសអាស៊ីនានាផ្សេងៗ។យើងមានសាលកំសាន្តសំរាប់ ពិធីការ ឬរាត្រីជួបជុំគ្នាមានបា និងខារ៉ាអូខេទៀតផង កន្លែងចតឡានមិនយកថ្លៃ ហើយមានសុវត្ថិភាពល្អ ។

新龍鳳大酒樓

$13.99 Per/person — Sunday Night Buffet

Restaurant & Bar
ភោជនីយដ្ឋាន និងបា



ភោជនីយដ្ឋាន ញូ ឆាយណា ភើល

Ballrooms for Wedding & Party
មានសាលកំសាន្តសំរាប់ពិធីការ ឬប្រជុំកំសាន្ត

ការ៉ាអូគី Karaoke
Thursday – Saturday Night
8 p.m. – 11:45 p.m.

មានឌិមស៊ុមរាល់ថ្ងៃ DAILY DIM SUM
Weekdays: 11 a.m.–3 p.m.
Weekends: 10 a.m.-3 p.m.

**BUSINESS HOURS: Mon - Wed 11 a.m. - 10 a.m./Thurs. & Fri. 11 a.m. - 12 Midnight / Sat. 10 a.m. - 12 Midnight / Sun. 10 a.m. - 10 p.m. Delivery Hours 11 a.m. - 9 p.m. min. $15 order plus $2 delivery.**

# កំណើនសេដ្ឋកិច្ចនៅកម្ពុជាតាមការព្យាករណ៍របស់ ADB



ដោយ : ពិន នារីពិទូ

សេដ្ឋកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជានឹងបន្តកើនឡើងគួរឱ្យកត់សម្គាល់តាមរយៈការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី។ កាលពីពេលថ្មីៗនេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានធ្វើសន្និសីទកាសែតមួយកាលពីនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ ប្រកាសពីលទ្ធផលនៃការព្យាករណ៍វិភាគអំពីម៉ាក្រូសេដ្ឋកិច្ចកម្ពុជាថា ផលិតផលក្នុងស្រុក GDP អាចនឹងកើនឡើង៦.៥ភាគរយនៅក្នុងឆ្នាំ២០១១ នឹងអាចកើនឡើងបន្ថែមចំនួន៦.៨ភាគរយនៅឆ្នាំ២០១២ រីឯទុនបំរុងអន្តរជាតិត្រូវបានព្យាករណ៍ថា នឹងកើនឡើងដល់២,៨៤ពាន់លានដុល្លារនៅក្នុងឆ្នាំ២០១១។

តាមប្រសាសន៍របស់លោក ឌុង ពូលឡង់ មន្ត្រីផ្នែកសេដ្ឋកិច្ចនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានឱ្យដឹងថា នៅក្នុងឆ្នាំ២០១០ លំហូរចូលនៃការវិនិយោគទុនពីបរទេសមានការងើបឡើងវិញគួរឱ្យកត់សំគាល់ផងដែរ គឺដោយការហូរចូលសរុបមានប្រមាណជិត៨រយលានដុល្លារ ដោយមានការកើនឡើងជាង៤០ភាគរយធៀបទៅនឹងឆ្នាំ២០០៩ ដែលជាឆ្នាំមួយដែលប្រទេសកម្ពុជា យើងបានទទួលរងពីវិបត្តិសេដ្ឋកិច្ចពិភពលោក ។ ការកើនឡើងលើវិស័យវិនិយោគទុននៅប្រទេសកម្ពុជាយើងភាគច្រើនលើវិស័យកាត់ដេរ វិស័យកសិកម្ម និងវិស័យធនាគារ ដោយសារមានការបណ្តាក់ទុនវិនិយោគថ្មីៗជាច្រើន ដូចជា ពីប្រទេសម៉ាឡេស៊ី និងប្រទេសផ្សេងៗទៀត ចំណែកឯប្រទេសដែលមកវិនិយោគច្រើនជាងគេនៅប្រទេសកម្ពុជាយើងគួរឱ្យកត់សំគាល់គឺ ប្រទេសវៀតណាម ដែលភាគច្រើននៃការវិនិយោគលើវិស័យកសិកម្ម និងប្រទេសចិន ភាគច្រើនវិនិយោគលើវិស័យកាត់ដេរ និងធនាគារ ។ នៅឆ្នាំ២០១១នេះយើងរំពឹងថាសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នឹងបន្តការកើនឡើងតទៅទៀត ជាពិសេស គឺលើវិស័យកសិកម្មដែលជាវិស័យមួយផ្តល់នូវសក្តានុពលច្រើន ហើយដែលវិស័យនេះបានក្លាយជាវប្បធម៌របស់ខ្មែរយើងតាំងពីយូរលង់ណាស់មកហើយនោះ។ ក្នុងខែសីហា ឆ្នាំ២០១០នេះ រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ ដើម្បីជំរុញផលិតកម្មក្នុងការនាំចេញអង្ករ ហើយនេះជាគោលនយោបាយថ្មីទាន់ពេលវេលា និងមានភាពងាយស្រួលដើម្បីជំរុញក្នុងការនាំចេញដូចនេះ ការវិនិយោគលើផលិតផលអង្ករយើងរំពឹងថានឹងមានការកើនឡើង ។ ចំណែកឯគុណវិបត្តិឬក៏ឧបសគ្គសេដ្ឋកិច្ចដែលប្រទេសកម្ពុជាយើងអាចប្រឈមមុខនាពេលអនាគតនោះគឺ ប្រទេសកម្ពុជាយើងពឹងផ្អែកលើម៉ាស៊ីនកំណើនសេដ្ឋកិច្ចលើវិស័យសំខាន់ៗមួយចំនួនដូចជាវិស័យកាត់ដេរ វិស័យទេសចរណ៍ វិស័យកសិកម្ម និងសំណង់ ដែលសំខាន់ហើយដែលបានធ្លាក់ចុះក្នុងឆ្នាំ២០០៩ ដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក ចំណែកវិស័យនីមួយៗ ដូចជា វិស័យកាត់ដេរពឹងផ្អែកលើទីផ្សារខាងក្រៅ ដូចនេះ បើសិនជាប្រជាជន ឬឧស្សាហកម្មនៅលើពិភពលោកមានការប៉ះពាល់ ដូចជា វិបត្តិសេដ្ឋកិច្ចនៅលើពិភពលោកនិងនៅលើប្រទេសមហាអំណាចដូចជាសហរដ្ឋអាមេរិកជាដើម ធ្វើឱ្យប្រជាជនទាំងនោះ មានការរឹតបន្តឹងក្នុងការចាយវាយដូចជា ការទិញសំលៀកបំពាក់ជាដើម ចំណែកឯអ្នកដែលចង់ធ្វើដំណើរមកលេងស្រុកខ្មែរ ក៏ត្រូវគិតគូរសារជាថ្មី



រូបថត RSA

ដោយធ្វើការពន្យាពេលក្នុងការធ្វើដំណើរទេសចរណ៍ជាដើម ដូចនេះសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើងពឹងផ្អែកលើកត្តាខាងក្រៅជាច្រើន ដូចនេះដើម្បីកាត់បន្ថយនូវការប្រឈមនឹងការប្រថុយប្រថានទាំងនេះ យើងត្រូវមានវិធានការទប់ទល់នូវប្រតិកម្មសេដ្ឋកិច្ច ដោយបន្ថែមនូវកំណើនសេដ្ឋកិច្ច ដោយត្រូវធ្វើឱ្យម៉ាស៊ីនកំណើនមានច្រើនបែប ជៀសវាងការពឹងផ្អែកម៉ាស៊ីនកំណើនសេដ្ឋកិច្ចពីមជ្ឈដ្ឋានខាងក្រៅហួសហេតុពេក ហើយភាគច្រើនប្រទេសយើងនាំចេញផលិតផលកសិកម្មស្រូវ ដោយមិនសូវនាំចេញអង្ករនោះទេ ដោយនាំចេញភាគច្រើន គឺស្រូវទៅកាន់ប្រទេសថៃ និងវៀតណាមជាដើម សំរាប់កម្ពុជាយើងការនាំចេញចេញស្រូវបែបនេះ មិនសូវជួយសេដ្ឋកិច្ចខ្មែរយើងឱ្យរីកលូតលាស់ប៉ុន្មានទេ ប៉ុន្តែបើយើងមានលទ្ធភាពក្នុងការកិនអង្ករដោយនាំចេញជំនួសស្រូវវិញ នោះនឹងបានតំលៃខ្ពស់ជាងនេះ ធ្វើឱ្យសេដ្ឋកិច្ចរីកចំរើនលឿនជាង នេះជាប្រតិកម្មសេដ្ឋកិច្ចនៅក្នុងម៉ាស៊ីនកំណើនដែលមានស្រាប់ ទន្ទឹមនឹងនោះដែរ យើងត្រូវងាកមកមើលមុខព្រួញសេដ្ឋកិច្ចម៉ាស៊ីនកំណើនផ្សេងទៀត ដូចជា ឧស្សាហកម្មធុនស្រាល ហើយកាលពីពេលថ្មីៗនេះអ្នកវិនិយោគទុនរបស់ប្រទេសជប៉ុនបានចាប់ផ្តើមមកវិនិយោគនៅប្រទេសកម្ពុជា ដោយគេមកដំឡើងផលិតផលអេឡិចត្រូនិចនេះជាឱកាសថ្មីដែលយើងត្រូវចាប់យក ដើម្បីធ្វើឱ្យម៉ាស៊ីនកំណើនរបស់កម្ពុជាពឹងផ្អែកលើមូលដ្ឋានកាន់តែមានភាពទូលំទូលាយជាងមុន ចំណែកឯបញ្ហាប្រឈមវិញ គឺយើងត្រូវបង្កើតសកម្មភាពសេដ្ឋកិច្ចឱ្យបានច្រើន ចំណែកឯដំណោះស្រាយ គឺយើងត្រូវចាប់យកឱ្យបាននូវបញ្ហាប្រឈម និងឱកាសដែលហុចឱ្យ។ ចំណែកចំណុចទីពីររដ្ឋាភិបាលត្រូវតែពង្រឹងឱ្យកាន់តែប្រសើរឡើងនូវការប្រកួតប្រជែងឈ្នះនៅលើទីផ្សារអន្តរជាតិ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសនៃការធ្វើអាជីវកម្មនៅប្រទេសកម្ពុជាយើងឱ្យកាន់តែប្រសើរឡើង ឱ្យការវិនិយោគមានភាពងាយស្រួល និងជួយកាត់បន្ថយថ្លៃដើមក្នុងការធ្វើអាជីវកម្ម ដែលរដ្ឋាភិបាលបច្ចុប្បន្នបានព្យាយាមយ៉ាងខ្លាំងក្លា ដូចជាចំណុចមួយគឺថ្លៃអគ្គិសនីនៅក្នុងប្រទេសយើងមានតម្លៃខ្ពស់ជាងប្រទេសជិតខាង ដូចនេះហើយធ្វើឱ្យថ្លៃដើមផលិតកម្មនៅប្រទេសយើងមានកំរិតមួយខ្ពស់ ហេតុនេះធ្វើឱ្យការប្រកួតប្រជែងឈ្នះរបស់ប្រទេសយើងនៅមានកំរិតនៅឡើយ ប៉ុន្តែយើងសង្ឃឹមថា នៅប៉ុន្មានឆ្នាំខាងមុខនេះ វារី-អគ្គិសនីនៅប្រទេសយើងនឹងកើតមានឡើងដែលជួយកាត់បន្ថយតំលៃអគ្គិសនីបច្ចុប្បន្ននេះ ដែលជាមធ្យមគឺ ១៦សេនក្នុងមួយគីឡូវ៉ាត់ ដូចនេះបើវារីអគ្គិសនីនៅប្រទេសកម្ពុជាចាប់ដំណើរការ ថ្លៃដើមនឹងកាត់បន្ថយជាបណ្តើរៗ ហេតុនេះជាបញ្ហាប្រឈមផង និងជាឱកាសផង ដែលយើងត្រូវចាប់យកដើម្បីពង្រឹង និងបន្តកំណើនសេដ្ឋកិច្ចឱ្យមានលំនឹងនាពេលខាងមុខនេះ ។

ចាប់តាំងពីធនាគារអភិវឌ្ឍន៍អាស៊ីមានវត្តមាននៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០១១នេះ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយមកឱ្យកម្ពុជា នាមជាប្រាក់កម្ចីការប្រាក់ទាបរួមជាមួយនឹងជំនួយឥតសំណងជាច្រើនទៀត ដែលមានចំនួនប្រហាក់ប្រហែលនឹងមួយពាន់បួនរយលានដុល្លារ ហើយមានវិស័យជាច្រើនដែលធនាគារអភិវឌ្ឍន៍អាស៊ីចូលរួមធ្វើការអភិវឌ្ឍ ហើយមុខព្រួញសំខាន់ៗផ្តោតលើការអភិវឌ្ឍផ្នែកហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសផ្នែកគមនាគមន៍ដឹកជញ្ជូន វិស័យអប់រំ និងវិស័យថាមពល ដែលជាចំបងបូករួមនឹងវិស័យផ្សេងៗទៀតផងដែរ។

បើតាមការព្យាករណ៍របស់ធនាគារពិភពលោក ដែលបានចេញផ្សាយនៅក្នុងរបាយការណ៍របស់ខ្លួនថាក្នុងឆ្នាំ២០១១ និងឆ្នាំ២០១២នេះ សេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា អាចកើនឡើង៦.៥ភាគរយលើវិស័យសំខាន់ៗដូចជាវិស័យកាត់ដេរ វិស័យទេស-ចរណ៍ និងវិស័យកសិកម្ម ធនាគារពិភពលោករំពឹងថា ផលទុនសរុបក្នុងស្រុក (GDP) នៅឆ្នាំ២០១១ នេះអាចនឹងកើនឡើងជាង១២ពាន់លានដុល្លារ ហើយក្នុងឆ្នាំ២០១២ អាចកើនឡើងជិត១៤ពាន់លានដុល្លារ ។ ប៉ុន្តែទោះជាមានការព្យាករណ៍អំពីការីកចម្រើនពីសេដ្ឋកិច្ចយ៉ាងនេះក្តី ក៏នៅតែមានការព្រួយបារម្ភពីសំណាក់រដ្ឋាភិបាល ជាពិសេស គឺការត្អូញត្អែរពីប្រជាជនអំពីអតិផរណា និងទំនិញឡើងថ្លៃដូចជាម្ហូបអាហារ ក៏ដូចជារបស់របរប្រើប្រាស់ដែលតែងតែកើនឡើងជាលំដាប់ ដូចជា ត្រី សាច់ បន្លែ ផ្លែឈើ ប្រេងសាំង ជាពិសេសប្រជាជននៅតាមជនបទដែលទទួលបានសេវាអប់រំ ព្រមទាំងសេវាសុខភាព នៅមានកំរិតទាប ទោះបីជារាជរដ្ឋាភិបាលកម្ពុជាបានខិតខំសាងសង់ហេដ្ឋារចនាសម្ព័ន្ធដូចជា ស្ពាន ថ្នល់ ដីកប្រឡាយ សាងសង់ សាលារៀន មន្ទីរពេទ្យនៅតាមបណ្តាលខេត្តនានាក៏ដោយ ក៏ប្រជាជននៅតាមបណ្តាជនបទ និងនៅតាមតំបន់ដាច់ស្រយាលខ្លះមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបញ្ជូនកូនឱ្យមករៀនសូត្រនៅសាលាបានដោយសារអាណាព្យាបាលមានជីវភាពដុនដាប ក្រខ្សត់ខ្លាំងពេក ហើយមានគ្រួសារក្រីក្រខ្លះ ដែលមានកូនច្រើនរហូតដល់ទៅជិតដប់នាក់ ឬលើសពីនេះនៅក្នុងបន្ទុកគ្រួសារ ហេតុនេះធ្វើឱ្យជីវភាពរបស់ពួកគាត់កាន់តែដុនដាបថែមទៀត ដែលធ្វើឱ្យប្រជាជននៅតាមជនបទទាំងនោះមានគន្លាតឆ្ងាយដូចជើងមេឃពីកំណើនសេដ្ឋកិច្ចនៅប្រទេសកំណើតរបស់ពួកគាត់ ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានថ្លែងនៅក្នុងសន្និសីទស្តីពីទស្សនៈវិស័យកម្ពុជា ថាសេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមកើនឡើង ចាប់តាំងពីឆ្នាំ២០១០ នឹងបន្តកើនឡើងនៅឆ្នាំ ២០១១បន្ថែមទៀត។

ប្រទេសកម្ពុជា ដែលចាត់ទុកថា ជាព្រះរាជា-ណាចក្រអច្ឆរិយតាមរយៈមានប្រាង្គប្រាសាទដ៏អស្ចារ្យ និងសំបូរបែប ដែលជាកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ ដែលត្រូវបានចុះបញ្ជីជាបេតិកភ័ណ្ឌពិភពលោករបស់អង្គការយូណេស្កូ រួមទាំងរមណីយដ្ឋានច្រើនស្មុគស្មាញ ដែលមានលក្ខណៈធម្មជាតិសុទ្ធសាធជាច្រើនកន្លែងគួបផ្សំនឹងបរិយាកាសដ៏បរិសុទ្ធលើទឹកដីសុវណ្ណភូមិ បានទាក់ទាញភ្ញៀវទេសចរណ៍បរទេសឱ្យចូលមកទស្សនាកំសាន្តដ៏ច្រើនអនេកនាបច្ចុប្បន្នក៏ដូចជានៅថ្ងៃអនាគត ដូចការព្យាករណ៍របស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ីទៅលើវិស័យទេសចរណ៍នេះផងដែរ ៕

## OLNEY STANDS AGAINST THE MAYOR'S BROWNOUT POLICY AFTER TWO CHILDREN ARE LOST TO FIRE

## ហ្វីឡាខាងជើងតវ៉ា

សហគមន៍ខ្មែរនៅឡូហ្គាន់ ហ្វីឡាដែលហៅខាងជើង តវ៉ាចំពោះការកាត់បន្ថយស្ថានីយពន្លត់អគ្គីភ័យដែលបណ្តាលឱ្យកូនខ្មែរពីររូបគឺ ភិតសិន និងខេវិនបាត់បង់ជីវិតពេលភ្លើងឆេះផ្ទះខ្លួន ។ សហគមន៍ខ្មែរ និងធ្វើបាតុកម្មនៅថ្ងៃច័ន្ទ ទី៩ខាងមុខ នៅមុខផ្ទះលោក តាំង ផេង 134 Spark St. ដែលត្រូវភ្លើងឆេះកាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១មុននោះ :

Monday May 9 - On February 22, 2011, the Taing family lost two children, Peterson and Kevin Taing, ages 9 and 7 respectively, to a fire that also destroyed their home. On that tragic day, Fire Engine 61, which had the most direct route to the family's home, was closed due to the City's Brownout policy...

In response, on Monday May 9th, we stand in support of the Taing family, and Local 22, who are working to keep all the fire stations open to give us the best possible chance of being safe from tragedy while we build for a better tomorrow. We will meet at 5PM at 134 Sparks Street, where Peterson and Kevin lost their lives ......we have decided to come together as a community and say "enough," and demand an end to the City's Brownout Policy which is jeopardizing the safety and lives of the people of Philadelphia.



Peterson & Kevin Taing

Mia-lia Kiernan, One Love Movement, 215 313 9298

Desi Burnette, Media Mobilizing Project, 215 518 7342

Rorng Sorn, Cambo-dian Association of Greater Philadelphia, **215 971 3657**

**រំលឹក និងសូមអញ្ជើញចូលរួម :**

បុណ្យ ១០០ថ្ងៃសម្រាប់ភិតសិន និងខេវិន និងប្រារព្ធឡើងនៅវត្តសុរិយារង្សី វត្តខាងជើង នៅថ្ងៃអាទិត្យ ទី២២ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង៩ព្រឹក ដល់១២ថ្ងៃត្រង់ ៕


# East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com



Skin Care Products | Tummy Tuck | Breast Lift | Beast Enlargement
Nose Surgery | Eyelid Surgery | Face Lift | Dermabrasion

ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន
អាការៈដូចជាៈ ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្ទង់ច្រមុះ
កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។
និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត

381 West Broadway South Boston, MA 02127
**(617) 464 - 0001**



# ការិយាល័យច្បាប់

## ERIK B.JENSEN P.C
*A Profesional Corporation*



**We Handle All INJURY CASES**
- Auto/Bus/Train/Motorcycle
- Slip and Fall / Workplace Accidents
- Medical Malpractice
- Nursing Home Neglect
- Dog Bites / Wrongful Death

**Criminal Defense—DUI**
Adult & Juvenile
Felonies / Misdemeanors / Drug Offenses
Weapons Charges / Murder / Manslaughter
Robbery / Burglary / Theft / Rape / Child Abuse
Drunk Driving / Traffic Violations

**BANKRUPTCY**
Sheriff Sales / Foreclosures / Repossessions
Credit Repairs / Tax Liens

**FAMILY**
Divorce / Support
Alimony / Child Custody
Protection From Abuse
Visitation / Adoptions

**BUSINESS**
Contracts / Negotiations
Litigation
Start-ups / Financing
Collections

**REAL ESTATE**
Commercial —Residential
Buying / Selling
Settlements / Closings

**TAX PROBLEM**
IRS Disputes / Tax Fraud
Audits / Liens / Levies
Tax & Estate Planning

Wills, Estates & Trusts Social Security

FREE Consultation ERIK B. JENSEN, P.C. Attorneys At Law

215-546-4700 24 HOUR AVAILABILITY 800-522-6606
1528 Walnut St., Suite 1401 Philadelphia

មានអ្នកបកប្រែភាសាខ្មែរ

Rely On Over
26 Years Of Experience



WWW.ERIKJENSENLAW.COM

we have Khmer staff



Voun Lay, BS
Marketing Coordinator
267-738-7006

# Yoo's Auto Service and Collision

## យូ បំរើសេវារថយន្ត

### នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

FREE ESTIMATES

យើងនឹងជួសជុលរថយន្តដ៏មានតម្លៃរបស់លោកអ្នក ឱ្យបានប្រសើរបំផុត តាមតែយើងធ្វើបាន ដើម្បីសុវត្ថិភាពលោកអ្នក មិនឱ្យខុសចិត្តឡើយ ។






189 W. Duncannon Ave. Phila., PA 19120

COUPON
$10 OFF TOWARD EMISSION AND STATE INSPECTION
Khmer Post

**ផ្នែកជាងម៉ាស៊ីន**

Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Inspection & Repairs
Muffler & More

**ផ្នែកជួសជុលតួរថយន្ត**

Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists

**ទូរស័ព្ទរក SAM 215-457-7777 ឬ 215-457-7779, Fax-215-457-7475**

# ខ្មែរប៉ុស្តិ៍ ស.រ.អា

"ខ្មែរប៉ុស្តិ៍" ត្រូវការជ្រើសរើសបុគ្គលិកផ្នែកទីផ្សារ នៅតំបន់ឡូវែល និងប្រូវីដិន មានកំរិតខ្ពស់ បើមានចំណាប់អារម្មណ៍សូមទំនាក់ទំនងមក :

សុបិន : (267) 253-3947, សែម : (781) 244-0522

# ខេនី គ្រូវេទមន្តដោយសម្មាធិ

មើលជម្ងឺនានា, ដោះមន្តស្នេហ៍, រំដោះគ្រោះ, ជួយគ្រួសារបែកបាក់,
មើលមុខរបររកស៊ី, ហុងស៊ុយ, ធ្វើយ័ន្តការពារខ្លួន ។
ចេះមន្តអាគមតាមរបៀប ចិន, យួន, ចាម ។
បើចង់ដឹងបន្ថែមសូមទំនាក់ទំនងតាមរយៈទូរស័ព្ទ:

**(540) 397-2603 ខ្ញុំឈ្មោះ "KENNY"**



# ការិយាល័យមេធាវី ដឺរេង នឹង បរូស្គី

## LAW OFFICE DOERING & BOROWSKY, LLC

**ទទួលការពារផលប្រយោជន៍លោកអ្នក ករណីទូទៅតាមផ្លូវច្បាប់ដូចជា :**

. ករណីបើរបរពាណិជ្ជកម្ម និងផ្ទេរប្រាក់ក្នុងមុខជំនួញ
. ករណីទិញលក់អចលនវត្ថុ ដូចជាផ្ទះសម្បែង ដីធ្លីជាដើម
. រើសអើងនៅកន្លែងធ្វើការ
. ករណីអន្តោប្រវេសន៍

**ធ្លាប់មានបទពិសោធន៍ខ្ពស់ _ផ្តល់សេវាជីនតាមវិជ្ជាជីវៈហើយតម្លៃក៏សមរម្យទៀតផង _យើងអាចមានអ្នកបកប្រែភាសាជូនលោកអ្នកបាន ។**



General practice law office handing matters in :
Corporations and business Transations
Real Estate
Work Place discriminations
Immigration
Experienced, professional service and reasonable rate Interpreter available

**Office: (215) 667-8118 1650 Market st. Ste 3600 Philadelphia, PA 19103**
**Cell: (215) 840-1364; Email: dblawyers@gmail.com**

# HELP WANTED

P/T office Asst, bi-lingual Vietnamese or Cambodian.General office work experience required. Opportunity for career advancement in the insurance field leading up Full time employment. Must pass background check.

Please call 215 533-6600

**បណ្ណជាវកាសែតខ្មែរប៉ុស្តិ៍**

ឈ្មោះ និងអាស័យដ្ឋានរបស់

ឈ្មោះ :...........................................................................
អាស័យដ្ឋាន : ....................................................................

**ខ្ញុំចង់បាន :**

☐ កាសែតខ្មែរប៉ុស្តិ៍ ១ខែ មាន២លេខ ៦ខែ $30 ១២ខែ $60 ឬ $70 អឺរ៉ូ សម្រាប់អឺរ៉ុប
☐ សៀវភៅឈ្មោះ ..............................តម្លៃ $..................
☐ ស៊ីឌីប្រវត្តិសាស្ត្រខ្មែរ ៤ ម៉ោង តម្លៃមួយសិត $30
ខ្ញុំភ្ជាប់សែក ឬ មនីអដ៌រ មក U.A.M.G តម្លៃ $..................
ផ្ញើមក U.A.M.G 438 LINDLEY AVE. PHILADELPHIA, PA 19120
**Phone : 267-253-3947**

តមកទំព័រទី ០១

# ព្រះរាជពិធីមង្គលការព្រះអង្គម្ចាស់...

នៅក្នុងភូមគ្រឹះវិស្សមកាលមួយ ដែលព្រះបរមរាជវាំងជួលក្នុងតម្លៃ ៤,៥០០អឺរ៉ូក្នុងមួយយប់នេះជាព័តិមានដែលរក្សាជាសម្ងាត់នៅបើមីងហ្គាម" ។ តែមុននឹងយាងចេញទៅបំពេញរាជកិច្ចរាត្រីទឹកឃ្មុំរបស់ព្រះរាជវាំងព្រះអង្គម្ចាស់ វិលីយាម ត្រូវយាងទៅបំពេញរាជកិច្ចការពារជាតិជាមួយកងទ័ពនេវី ផ្នែកអាកាស Royal Air Force នៅថ្ងៃអង្គារ ទី៣ ខែឧសភានេះសិន។ អ្នកសង្កេតការណ៍និយាយថា នាងគឺជាព្រះរាជទីនាំងដែលដឹកចម្លងបន្តព្រះរាជវង្សនៃព្រះរាជាណាចក្ររបស់នាង..."។

លោក វិតទ័រ អុយហ្គោ ទាយទុកថា ព្រះជាយានឹងពរពោះបុត្រា ឬបុត្រីមុន៩ខែខាងមុខនេះ ដូច្នេះព្រះរាជអាពាហ៍ពិពាហ៍រវាងព្រះអង្គម្ចាស់ វិលីយាម និងនាង ខេត នឹងអាចសម្រួលការឡើងសោយរាជ្យរបស់ព្រះអង្គម្ចាស់ វិលីយាម ថ្វីបើព្រះអង្គពុំបានត្រូវចាត់ទុកតាម



ព្រះអង្គម្ចាស់ វិលីយាម ជាអ្នកបើកអេលីកូ







ពិធីព្រះរាជមង្គលការរាជវង្សនេះ ព្រះអង្គម្ចាស់នឹងព្រះជាយា នឹងប្រសូត្របានបុត្រី ឬបុត្រា ដែលនឹងស្នងរាជបន្តជាស្តេចចក្រភពអង់គ្លេស ក្នុងពិធីសោយភោជនាហាររាត្រីព្រះអង្គម្ចាស់ ស្ហាល (Charles) ជាព្រះបិតា និងជាអនាគតព្រះមហាក្សត្រលំដាប់ទី១ បានមានព្រះបន្ទូលថា "ខ្ញុំមានសំណាង ដោយបានទទួលនាង ខេត ក្នុងរង្វង់ព្រះរាជវង្ស ដែលនឹងបន្តកេរ្តិ៍តម្រារបស់រាជវង្សនៃចក្រភពអង់គ្លេស"។ កាសែត ដេលី មេល បានលើកសម្តីនាង ខេត ដែលបានសច្ចាថា "នាងមានមោទនភាព ប្តេជ្ញារក្សាភាពជានារី និងចរិកមិនខុសពីគេឯងទាំងពួង... នាងរក្សាសោភ័ណភាព និងសេចក្តីទន់ភ្លន់តាមធម្មជាតិរបស់នាង... លំដាប់ទី១នៃព្រះរាជវង្ស ដែលត្រូវឡើងគ្រងរាជក៏ដោយ ។ បើយោងតាមវិទ្យុ BBC ព្រះអង្គម្ចាស់ វិលីយាម ស្ថិតនៅលំដាប់ថ្នាក់ព្រះរាជវង្សទីពីរនៃអង្គត្រកូលដែលត្រូវសោយរាជ្យ ។

អ្នកវិភាគបានបញ្ចប់កិច្ចពិភាក្សារបស់គេថា "ព្រះអង្គម្ចាស់ វិលីយាម ពុំមានអ្វីខុសពីយោធាអ្នកបើក អេលីកូ អង់គ្លេសម្នាក់ដូចអស់បុគ្គលិកទាហានឯទៀតៗដែរ" ទីបំផុតគេនិយាយថា "ព្រះអង្គម្ចាស់ និងព្រះជាយា និងមិនយាងទៅបរទេសទេ បើភ្ជាប់ទៅនឹងបញ្ហាសេដ្ឋកិច្ចជាតិ មុននឹងស្តេចយាងត្រឡប់ទៅបន្តបេសកកម្មបំរើកងនេវី RAF នៅលើមូលដ្ឋានជើងទឹក នៅកោះមាលូវិន MALOUVING - ARGENTINA ៕



Massachusetts Council on
Compulsive Gambling
*We understand the problem. We can help.*

ក្រុមប្រឹក្សារដ្ឋម៉ាសាឈូសេតសំរាប់
ការញៀនល្បែងស៊ីសង

"ប្រសិនបើលោកអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់
មានបញ្ហាញៀនល្បែងស៊ីសង សូមទូរស័ព្ទមកលេខ
ខាងក្រោម អាចជួយជាអ្នកសម្ងាត់ ហើយ
សួររកសៀវភៅសម្រាប់ឱ្យអាចជួយខ្លួនឯងបាន
ជាភាសាខ្មែរដោយឥតគិតថ្លៃ"

1-857-383-3577

ជំហានដំបូងរបស់អ្នកឆ្ពោះទៅកាន់ការផ្លាស់ប្តូរ
www.asianproblemgambling.org





(រូបថត សំណាង)



ក្រុមនារី និងកុមារីបង្ហាញម៉ូតសំលៀកបំពាក់ខ្មែរ សុផាលីន



តមកពីទំព័រទី ០១

# ខ្មែរប៉ុស្តិ៍ចូលឆ្នាំថោះជាមួយ...

សុបិន និង សំខុន បានត្រូវអញ្ជើញឱ្យមកសំដែងការចាប់អារម្មណ៍ ទទួលភ្ញៀវ រួចមកក៏អញ្ជើញលោកស្រីអភិបាលក្រុងលីន ជូឌីត កិណើឌី ដែលបានថ្លែងអរគុណដល់ខ្មែរប៉ុស្តិ៍ ស.រ.អា ដែលបានចូលខ្លួនមកបំរើវិស័យព័ត៌មាននៅលីន ហើយបានបន្តថា "កាលពីសម័យទាមទារឯករាជ្យរបស់អាមេរិកាំង គឺសារព័ត៌មានសេរី គឺជាវិស័យមួយដែលបានកើតមុនគេសម្រាប់ផ្តល់ដំណឹងសំខាន់ៗជូនពលរដ្ឋ..." ហើយលោកស្រីមានការរីករាយដោយឃើញរាត្រីនេះក្រុងលីន និងរីវៀ បានត្រូវសហគមន៍ខ្មែរតភ្ជាប់គ្នា ដោយមានវត្តមានលោកអនុប្រធាន អែរ៉ា នៃទីក្រុងរីវៀ ក៏មកចូលរួមនៅទីនេះដែរ ។ លោកស្រីបានសុំអញ្ជើញបងប្អូនខ្មែរនៃសហគមន៍ខ្មែរ ឱ្យចូលរួមសំណេះសំណាល ពិសារទឹកតែសាលាក្រុង ដែលរៀបចំឡើងដោយជំនួយការរបស់លោក គីរីរដ្ឋ ជាឱកាសប្រាស្រ័យទាក់ទងរបស់សាលាក្រុងជាមួយពលរដ្ឋខ្មែរទៀតផង ។

ចំណែកឯលោក អែរ៉ា ណូវ៉ូសែលស្គី អនុប្រធានក្រុងរីវៀ ដែលជាមិត្តជិតស្និតរបស់សហគមន៍ខ្មែរនៅទីនោះ បានរំលឹកថា "សាលាក្រុងបានប្រារព្ធពិធីលើកទង់ជាតិខ្មែរនៅសាលាក្រុងរីវៀ នាឱកាសពិធីបុណ្យដ៏ធំសម្រាប់សហគមន៍ខ្មែរនាឱកាសចូលឆ្នាំថ្មីនេះដែរ...។

លីន និងរីវៀ នៅជាប់គ្នា ហើយសហគមន៍ខ្មែរ បូក បញ្ចូលគ្នាក្លាយជាសហគមន៍ដ៏ធំមួយមានពលរដ្ឋសហគមន៍ប្រមាណបីម៉ឺននាក់ ដែលប្រកបមុខរបរសមរម្យក្នុងបរិដ្ឋានស្រស់ស្អាតសមតែជាសហគមន៍ដ៏ខ្លាំងមួយ ប៉ុន្តែសមាជិកសហគមន៍បាននិយាយថា ពុំទាន់មានសមាគមខ្មែរមួយជាតំណាងឱ្យបងប្អូនខ្មែរនៅទីនោះនៅឡើយទេ

ម្លោះហើយក៏មានសម្លេងរ៉ាតរបាយបន្តិចបន្តួចប៉ុណ្ណោះជាភាពតំណាងរបស់ខ្លួន។

រាត្រីចូលឆ្នាំខ្មែរប៉ុស្តិ៍ ស.រ.អា នោះជាឱកាសដ៏តិចតួចមួយតែតាមរយៈ **អគ្រា** ខ្មែរប៉ុស្តិ៍ បានបង្ហាញខ្លួនក្រុមតំណាងសហគមន៍ មានក្រុមអ្នកធ្វើការបំរើសហគមន៍ ក្រុមគ្រូបង្រៀន ក្រុមពាណិជ្ជករ ក្រុមអ្នកនយោបាយ ខ្មែរម្ចាស់ស្រុក ក្រុមសិល្បករ ក្រុមអ្នកស្ម័គ្រចិត្តទទួលភ្ញៀវគ្រប់ៗគ្នា។ ក្រុមតន្ត្រីសម័យវ៉ាយោនា រាត្រីនោះក៏បានកំដរបំពេរអារម្មណ៍ភ្ញៀវកិត្តិយសទាំងអស់បានយ៉ាងប្រសើរ ក្នុងរាត្រីដែល គេនាំគ្នាបំភ្លេចភាពចាស់ទុំ ភាពរើសអើង ហើយពត់ពេនខ្លួនតាមចង្វាក់ភ្លេង ហើយនៅសល់តែភាពរីករាយក្នុងគ្រួសារតែមួយតែប៉ុណ្ណោះ ។

រាត្រីចូលឆ្នាំថោះ ជាមួយខ្មែរប៉ុស្តិ៍ ស.រ.អា បានបញ្ចប់ទៅដោយបន្សល់ទុកនូវអនុស្សាវរីយ៍ល្អៗនៃពិធីដង្ហែរម៉ូត សុផាលីន ដោយយុវនារី និងកុមារីក្នុងសំលៀកបំពាក់ខាន់ឃើញយូរមកហើយ ឬពុំដែលឃើញសោះ អនុស្សាវរីយ៍នៃម្ហូបអាហារក្លិនឈ្ងុយឆ្ងាញ់មកពីហាងឆុបស៊ុក ឬហាងអង្គរវត្ត សម្លេងភ្លេងដ៏ពីរោះរបស់វ៉ាយោតន្ត្រី ហើយមានភ្ញៀវខ្លះនាំយកទៅផ្ទះនូវរង្វាន់តម្លៃជាទឹកប្រាក់៩ពាន់ដុល្លារ មកពីមន្ទីរកែសម្ផស្ស East Cost Center ដែលចែកជារង្វាន់ធំប័ណ្ណ $2.000 បានទៅហាងបាត់ដំបង រង្វាន់លេខ២ $1.000 បានទៅអ្នកស្រុកបារាំង និងរង្វាន់ផ្សេងៗទៀត មាន $500 បានទៅភ្ញៀវ ១០នាក់ទៀតប្រកបដោយទឹកមុខរីករាយ ៕



ពីឆ្វេងទៅស្តាំ› អគ្រា, លោកអភិបាលរងក្រុងរីវៀ អែរ៉ា, សុបិន, ប៊ុនណារ៉ូ, ពិនសំខុន



(រូបថត វិមល) រង្វាន់លេខ២ ប័ណ្ណ១០០០ដុល្លារម្នាក់



រាំកំសាន្តជាមួយក្រុមតន្ត្រីវាយោ



(រូបថត វិមល) រង្វាន់លេខ៣ ប័ណ្ណ៥០០ដុល្លារម្នាក់



ក្រុមស្ម័គ្រចិត្តជួយបំរើម្ហូបភ្ញៀវ



(រូបថត វិមល) រង្វាន់លេខ១ ប័ណ្ណ២០០០ដុល្លារម្នាក់ មកពី East Cost Center





លោកស្រីអភិបាលក្រុងលីន

លោក គីរីរដ្ឋ